ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# សទ្ទានុក្រម

# វេជ្ជសាស្ត្រ

## ខ្មែរ-អង់គ្លេស-បារាំង

# LEXICON
# OF
# MEDICINE
## Khmer-English-French

ក្រុមប្រឹក្សាជាតិភាសាខ្មែរ

គណៈកម្មការសុខាភិបាល

២០១៩

**បោះពុម្ពលើកទី១** ចំនួន២ ៤០០ច្បាប់
នៅរោងពុម្ព ជី.អ៊ី.ធី.ប៊ីហ្សនេស
ផ្ទះលេខ២៣២០ ផ្លូវ៤៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)
អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរសព្ទដៃ : ០១២ ៨៦៣ ៩២០, ០១២ ៥៨៩ ៥៤៩, ០៩២ ៨៩២ ៣៤៣
អ៊ីមែល : ncklofrac@gmail.com
វេបសាយ : www.nckl.gov.kh

# សមាសភាព
# គណៈកម្មការសុខាភិបាល

| | |
|---|---|
| ១- ឯកឧត្តមបណ្ឌិតសភាចារ្យ សំ សោភាន់ | ប្រធាន |
| ២- ឯកឧត្តម នុត សម្បត្តិ | អនុប្រធាន |
| ៣- ឯកឧត្តម ប៉ែន ប៊ួនពីរ | សមាជិក |
| ៤- លោកជំទាវ ឡុង ថុល | សមាជិក |
| ៥- លោកបណ្ឌិត តាំង ស៊ិន | សមាជិក |
| ៦- លោក អាត ធារ៉ា | សមាជិក |
| ៧- លោកវេជ្ជបណ្ឌិត ស្វាយ កាម៉ុល | សមាជិក |
| ៨- លោក ជុំ គឹមរ៉ុង | សមាជិក |
| ៩- លោក ម៉ាន់ សុងញ្ញា | សមាជិក |
| ១០- លោក ឃឹម វិច្ឆិកា | ជំនួយការខាងភាសា |

# បុព្វកថា

ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)នៃរាជបណ្ឌិត្យសភាកម្ពុជាមានភារកិច្ចស្វែងរកឯកភាពជូនភាសាខ្មែរ ទាំងអក្ខរាវិរុទ្ធ ទាំងអំណាន និងពាក្យពេចន៍។ ទន្ទឹមនឹងការស្វែងរកឯកភាពនេះ ក្រុមប្រឹក្សាជាតិភាសាខ្មែរក៏មានតួនាទីបង្កើតបច្ចេកសព្ទថ្មីៗទាក់ទងនឹងជំនាញផ្សេងៗផងដែរ។

វិស័យសុខាភិបាលជាវិស័យមួយដ៏សំខាន់ក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ហើយបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃវិស័យសុខាភិបាល បច្ចេកសព្ទវេជ្ជសាស្ត្រថ្មីៗក៏ត្រូវបានអ្នកជំនាញខាងវិស័យនេះបង្កើតឡើង និងប្រើប្រាស់ទៅតាមតម្រូវការរបស់ខ្លួន។

បច្ចេកសព្ទវេជ្ជសាស្ត្រដែលគណៈកម្មការសុខាភិបាលនៃក្រុមប្រឹក្សាជាតិភាសាខ្មែរបានស្នើអនុម័ត នៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ហើយបោះពុម្ពជាសទ្ទានុក្រមនេះពិតជាមានសារៈសំខាន់ណាស់ក្នុងការសិក្សាស្រាវជ្រាវ ចែករំលែកចំណេះដឹងខាងវេជ្ជសាស្ត្រ ព្រមទាំងរួមចំណែកអភិវឌ្ឍនិងស្វែងរកឯកភាពជូនភាសាខ្មែរផងដែរ។

សូមអ្នកស្រឡាញ់ភាសាជាតិទទួលយកសទ្ទានុក្រមនេះទៅប្រើប្រាស់ក្នុងជំនាញរបស់ខ្លួនដើម្បីឱ្យភាសាយើងសម្បូរពាក្យពេចន៍និងរីកចម្រើនដូចភាសានៃប្រទេសជឿនលឿនក្នុងលោក។

ថ្ងៃច័ន្ទ ៦កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

បណ្ឌិតសភាចារ្យ **សុខ ទូច**

# **អារម្ភកថា**

គណៈកម្មការបច្ចេកទេសទាំង១៧ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.) មានភារកិច្ចស្រាវជ្រាវ ចងក្រង និងបង្កើតពាក្យទៅតាមជំនាញរៀងៗខ្លួន។ គណៈកម្មការបច្ចេកទេសនីមួយៗបានស្នើបច្ចេកសព្ទរបស់ខ្លួននៅក្នុងការប្រជុំអនុម័តពាក្យរបស់ ក.ជ.ភ.ខ.។ ពាក្យដែលបានអនុម័តរួចត្រូវបោះផ្សាយក្នុងព្រឹត្តិបត្ររបស់ ក.ជ.ភ.ខ. ហើយបន្ទាប់មក ពាក្យទាំងនោះត្រូវប្រមូលចងក្រងដើម្បីបោះពុម្ពជាសទ្ទានុក្រម។

នៅឆ្នាំ២០១៥ គណៈកម្មការសុខាភិបាលបានស្នើអនុម័តបច្ចេកសព្ទលើកទី១ បានចំនួន ២២៩ពាក្យ ហើយនៅឆ្នាំ២០១៨ គណៈកម្មការសុខាភិបាលបានស្នើអនុម័តបច្ចេកសព្ទលើកទី២ បានចំនួន១៤១ពាក្យ។ លេខាធិការដ្ឋាននៃ ក.ជ.ភ.ខ. បានប្រមូលបច្ចេកសព្ទដែលអនុម័តទាំងពីរលើកមកបញ្ចូលគ្នាសរុបទាំងអស់ចំនួន៣៧០ពាក្យ ដើម្បីរៀបចំបោះពុម្ពនិងផ្សព្វផ្សាយនៅក្នុងសទ្ទានុក្រមនេះ។

ក.ជ.ភ.ខ. សង្ឃឹមថា សទ្ទានុក្រមវេជ្ជសាស្ត្រនេះជាវិភាគទានមួយដ៏សំខាន់សម្រាប់សាធារណជនយកទៅប្រើប្រាស់តាមតម្រូវការដើម្បីអភិវឌ្ឍចំណេះដឹងនិងជួយសម្រួលដល់ការប្រើប្រាស់បច្ចេកសព្ទវេជ្ជសាស្ត្រឱ្យឯកភាពគ្នាទាំងអក្ខរាវិរុទ្ធនិងន័យផងដែរ។

ក.ជ.ភ.ខ. មិនអាចដំណើរការបានទេ បើសិនគ្មានការគាំទ្រនិងការលើកទឹកចិត្តពីសំណាក់រាជរដ្ឋាភិបាល។ អាស្រ័យហេតុនេះ ក្នុងនាម ក.ជ.ភ.ខ. ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំរាជរដ្ឋាភិបាលដែលបានឧបត្ថម្ភគាំទ្រដល់ ក.ជ.ភ.ខ. យើង ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។

ថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិត **ហ៊ាន សុខុម**

# ក

**កង្វាក់/អាម៉ូរ៉ូស**
អ. amaurosis
បារ. amaurose( f. )

អាការៈងងឹតមើលមិនឃើញរបស់ភ្នែក តែបនាសម្ព័ន្ធគ្រាប់ភ្នែកនៅធម្មតា។

**កញ្ជ្រឹល**
អ. measles, morbilli, rubeola
បារ. rougeole ( f. )

រោគឆ្លងម៉្យាង ច្រើនកើតលើកុមារ បណ្តាលមកពីវីរុស morbilli បង្កឱ្យស្បែកមានកន្ទួលតូចៗពណ៌ក្រហម ក្អក ហៀរសំបោរ គ្រុនក្តៅ ឈឺបំពង់ក។ល។ ឧ. កុមារនេះបានចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹលរួចហើយ។

**កន្ថោរពេទ្យ/បាសាំងពេទ្យ**
អ. bedpan
បារ. bassin de lit

បរិក្ខារវេជ្ជសាស្ត្រ ជាកន្ថោរមានទ្រង់ទ្រាយសំប៉ែត សម្រាប់ឱ្យអ្នកជំងឺបន្ទោបង់នៅលើគ្រែ។

**កន្ទាលត្រអាក**
អ. urticaria/hives
បារ. urticaire ( f. )

កន្ទួលឃ្មឹលជាបន្ទះតិចឬច្រើននៅលើស្បែកមាន ឬ គ្មានពណ៌ក្រហមបណ្តាលឱ្យរមាស់កើតឡើងដោយប្រតិកម្មអាឡែហ្ស៊ី (réaction allergique)។ ឧ១- ការប៉ះពាល់ជាមួយនឹងដើមកន្ទេចអាល ឬ វល្លិខ្ញែរបណ្តាលឱ្យឡើងកន្ទាលត្រអាកលើស្បែកត្រង់កន្លែងប៉ះនោះ។ ឧ២- ប្រតិកម្មអាហារ ឱសថ និងរោគសញ្ញានៃជំងឺបរាសិតមួយចំនួនបណ្តាលឱ្យចេញកន្ទាលត្រអាកនៅលើស្បែក។

**កម្រិនអាកទែ/ អាកទែរីយ៉ូសក្លេរ៉ូស**
អ. arteriosclerosis
បារ. artériosclérose (f.)

១-អាការៈក្រាស់រឹង និង បាត់ភាពយឺត (élasticité) នៃអាកទែដែលបង្កឡើងដោយអត្រាកាល់ស្យូមឡើងខ្ពស់ក្នុងចរន្តឈាមដែលភាគច្រើនកើតឡើងចំពោះមនុស្សវ័យចំណាស់។
២- អាការៈក្រាស់រឹងនៃផ្នែកណាមួយឬច្រើននៃអាកទែដែលបង្កឡើងដោយកំណកសារធាតុខ្លាញ់អាតេរ៉ូម ស្ថិតនៅក្នុងអាកទែរយៈពេលយូរ ដែលបង្កឱ្យទៅជាអាតេរ៉ូសក្លេរ៉ូស (athérosclérose)។

**កម្សោយសាច់ដុំ**
អ. myasthenia
បារ. myasthénie (f.)

អាការៈចុះខ្សោយកម្លាំងចលនាសាច់ដុំបណ្តាលមកពីមូលហេតុច្រើនយ៉ាង។

**កាយវិភាគវិទ្យា/ អាណាតូមី**
អ. anatomy
បារ. anatomie (f.)

វិទ្យាសាស្ត្រសិក្សាអំពីរចនាសម្ព័ន្ធនៃសរីរាង្គមនុស្ស និងសត្វ។

**ការកកឈាម**
អ. blood coagulation/ bloodclotting
បារ. coagulation sanguine (f.)

បម្រែបម្រួលឈាមពីរាវទៅពាក់កណ្តាលរឹងដែលអាចកើតមាននៅក្នុង ឬក្រៅសរសៃឈាម។

**ការកន្ត្រាក់សាច់ដុំ** អាការៈទាញកញ្ជក់នៃសាច់ដុំដែលរំញោចដោយប្រព័ន្ធប្រសាទឬដោយមូលហេតុផ្សេងៗ។
អ. muscle contraction
បារ. contraction musculaire (f.)

**ការកន្នែក/អាប់ដុកម្ម** ចលនាសរីរាង្គដែលទាញចេញទៅខាងក្រៅខុសពីទម្រង់ដើម។
អ. abduction
បារ. abduction (f.)

**ការក្អែ** ដំណើរវិលត្រឡប់នៃអាហារពីក្រពះឬបំពង់អាហារមកតាមមាត់តែមិនមែនជាការក្អួតទេ។ ឧ.ការក្អែច្រើនកើតលើទារក និងកុមារតូចៗក្រោយពេលបៅរួច។
អ. regurgitation
បារ. régurgitation (f.)

**ការខ្ទាំ/កុងទុយស្យុង** របួសម្យ៉ាងដែលបណ្ដាលមកពីគ្រោះថ្នាក់ធ្ងន់ធ្ងរធ្វើឱ្យខ្ទេចជាលិកាក្នុងសរីរាង្គណាមួយ ប៉ុន្តែមិនមានរហែកស្បែកឬស្រោមព័ទ្ធជុំវិញ។
អ. contusion
បារ. contusion (f.)

**ការចាក់ម្ជុលវិទ្យាសាស្ត្រ/អាគុយពង់ទួរ** វិធីចាក់ម្ជុលផ្ទារចូលតាមស្បែកចំខ្សែម៉េរីឌីយាង (méridien) នៃសរីរាង្គដែលឈឺក្នុងគោលបំណងរករោគវិនិច្ឆ័យ ឬធ្វើការព្យាបាលជំងឺពុំរ៉ៃមួយចំនួនតាមក្បួនវេជ្ជសាស្ត្របុរាណចិន។
អ. acupuncture
បារ. acupuncture (f.)

**ការចាល់/រ៉េតង់ស្យុង**
អ. retention
បារ. rétention (f.)

អាការៈនៃសរីរាង្គដែលមិនអាចមានលទ្ធភាពបញ្ចេញចោលឱ្យអស់នូវសារធាតុផ្ទុក (រឹង រាវ ឬឧស្ម័ន) របស់វា។ ឧ. រ៉េតង់ស្យុងទឹកមូត្រនៅក្នុងប្លោកនោមដែលបណ្ដាលមកពីការចាល់នៅត្រង់បង្ហូរនោមអាចបង្កឱ្យមានគ្រោះថ្នាក់។

**ការចុកពោះ/កូលិក**
អ. colic
បារ. colique (f.)

អាការៈឈឺចុកចាប់ក្នុងធិទ្ធដ្ឋានពោះ (cavité abdominale)។ ឧ. ក្នុងករណីស្ទះពោះវៀនធំអ្នកជំងឺមានការចុកពោះយ៉ាងខ្លាំងក្លា។

**ការចុកវក្កំ/ការចុកតម្រងនោម**
អ. renal colic
បារ. colique rénale
colique néphrétique

អាការៈឈឺចុកចាប់យ៉ាងស្រួចស្រាល់នៅចង្កេះផ្នែកខាងឆ្វេង ឬស្ដាំដែលមានលក្ខណៈឈឺចាក់ចុះក្រោមទៅរកប្រដាប់បន្តពូជខាងក្រៅ ឬផ្ទៃខាងក្នុងនៃភ្លៅដោយសារការស្ទះផ្លូវទឹកមូត្រដែលភាគច្រើនបណ្ដាលមកពីមានក្រួស។ ឧ.ការចុកតម្រងនោមខាងស្ដាំអាចច្រឡំជាមួយនឹងការចុកថ្លើម (colique hépatique) ប៉ុន្តែការចុកថ្លើមមានអាការៈឈឺចាក់មករកស្មាស្ដាំ។

**ការឈឺសន្លាក់**
អ. arthralgia
បារ. arthralgie (f.)

ការឈឺចុកចាប់ក្នុងសន្លាក់ដែលបង្កដោយជំងឺច្រើនយ៉ាង។ ឧ. ជំងឺគ្រុនសន្លាក់ (rhumatisme) បង្កឱ្យមានការឈឺសន្លាក់ច្រើនកន្លែង។

**ការឈឺសាច់ដុំ**
អ. myalgia/
myodynia
បារ. myalgie/
myodynie (f.)

អាការៈឈឺចុកចាប់នៅក្នុងសាច់ដុំដោយសារមូលហេតុច្រើនយ៉ាង ដូចជា ការឈឺសាច់ដុំពេលមានជំងឺផ្ដាសាយធំ(grippe)។

**ការញៀន**
អ. addiction
បារ.addiction/
pharmacodé
pendance (f.)

អាការៈដែលមនុស្ស ឬ សត្វមិនងាយបោះបង់បាននូវសារធាតុញៀន(drogue)ដែលធ្លាប់បានប្រើរួចហើយ។ ឧ. អាភៀននិងកញ្ឆាធ្វើឱ្យមានការញៀនដែលមិនងាយបោះបង់បានក្រោយពេលប្រើវាយូរមកហើយ។

**ការត្រាំ**
អ. balneation
បារ. balnéation(f.)

វិធីពន្លិចសព៌ាង្គកាយមួយផ្នែកឬទាំងមូលក្នុងទឹក ឬ ក្នុងសូលុយស្យុងផ្សេងៗក្នុងគោលបំណងព្យាបាល។

**ការត្រាំព្យាបាល**
អ. balneotherapy
បារ. balnéothérapie(f.)

វិធីព្យាបាលជំងឺដោយការត្រាំ។

**ការត្អើក**
អ. hiccough
បារ. hoquet (m.)

ដំណើរកន្ត្រាក់នៃសាច់ដុំរបាំងទ្រូង (diaphragme) ដោយអចេតនាបង្កឱ្យមានការបញ្ចេញខ្យល់ និងសំឡេងតាមមាត់ជាសូរអឹកៗ។ ឧ. ជំងឺមហារីកបំពង់អាហារបង្កឱ្យមានការត្អើកជាប្រចាំ។

**ការធ្លាក់ស/ឡឺកូរ៉េ**
អ. leukorrhea
បារ. leucorrhée (f.) / pertes blanches

អាការៈធ្លាក់រំអិលពណ៌សតាមផ្លូវបន្តពូជរបស់ស្ត្រីក្នុងចន្លោះពេលមានរដូវ ពេលមានគភ៌ ពេលបំបៅកូននិងក្រោយពេលអស់រដូវ។ ឧ. ការធ្លាក់សមានពណ៌ផ្សេងក្រៅពីពណ៌ស និង ក្លិនខុសធម្មតា ព្រមទាំងមានរមាស់ទ្វារមាសជាអាការៈបញ្ជាក់ពីការរលាក ឬ មានជំងឺប្រដាប់បន្តពូជស្ត្រី។

**ការបង្កកំណើត/កំណកំណើត**
អ. fertilization
បារ. fécondation (f.)

ជំនួបរវាងស្ពែម៉ាតូសូអ៊ីត (spermatozoïde) និង អូវុល (ovule) ចំពោះមនុស្សឬសត្វ រវាងអង់តេរ៉ូសូអ៊ីត (anterozoïde) និង អូអូស្វ៊ែ (oosphère) ចំពោះ រុក្ខជាតិបង្កើតបានជាកោសិកាថ្មីមួយហៅថា ស៊ីហ្គូត (zygote)។ ឧ. ការបង្កកំណើតអាចប្រព្រឹត្តទៅបានលុះត្រាតែមានការជួបគ្នារវាងកាម៉េតឈ្មោលនិងកាម៉េតញី។

**ការបាក់ឆ្អឹង/បំណាក់ឆ្អឹង**
អ. fracture
បារ. fracture (f.)

ការបាក់ដាច់ ឬ បែកបាក់ដោយអន្លើ ឬ ដោយផ្នែកទាំងអស់របស់ឆ្អឹង។ ឧ. ក្រោយពីអស់រដូវស្ត្រីដែលពុំបានទទួលសារជាតុកាល់ស្យូម និង ផូស្វ័រឱ្យបានគ្រប់គ្រាន់ងាយទទួលរងការបាក់ឆ្អឹង។

**ការផ្តាច់គភ៌**

អ. conceptus interruption

បារ. interruption de conception

ការបញ្ចប់ការអភិវឌ្ឍគភ៌នៅក្នុងផ្ទៃដោយចេតនា។ ឧ.ការរំលូតកូនជាវិធីមួយក្នុងការផ្តាច់គភ៌។

**ការពន្យារកំណើត/ កុងត្រាសិបស្យុង**

អ. contraception

បារ. contraception( f. )

វិធីបង្ការមិនឱ្យមានកំណគភ៌នៅក្នុងផ្ទៃម្តាយ។ ឧ.ការប្រើស្រោមអនាម័យជាវិធីមួយក្នុងចំណោមវិធីជាច្រើននៃការពន្យារកំណើត។

**ការភ្លាត់ឆ្អឹង**

អ. luxation

បារ. luxation( f. )

ដំណើរឃ្លាត ឬភ្លាត់ ឬរបូតក្បាលឆ្អឹងពីទីតាំងដើមបណ្តាលមកពីការដួល ឬការប៉ះទង្គិច។ ឧ.កីឡាករបាល់ទាត់ច្រើនរងគ្រោះថ្នាក់ដោយការភ្លាត់ឆ្អឹង។

**ការមានរដូវ**

អ. menorrhea

បារ. ménorrhée ( f. )

ការហូរឈាមនិងសារធាតុផ្សេងៗពីក្នុងស្បូនរបស់ស្ត្រីនៅពេលមានរដូវ។

**ការរុំបង់**

អ. bandage

បារ. bandage ( m. )

វិធីរុំរបួស ឬ ដំបៅដោយប្រើបង់រុំដើម្បីទប់ឱ្យនឹង ឬ ទប់លំហូរឈាម។

**ការមិនស្រេកទឹក/អឌីបស៊ី**
អ. adipsia
បារ. adipsie (f.)

លក្ខណៈធម្មជាតិរបស់មនុស្សមួយចំនួនតូចដែលមិនចង់ផឹកទឹកក្នុងរយៈពេលខ្លីឬវែង (ថ្ងៃ ឬ សប្តាហ៍) ប៉ុន្តែមិនមែនជាជំងឺទេ។

**ការរមួលសន្លាក់**
អ. distortion
បារ. distorsion (f.)

របួសម្យ៉ាង ដែលធ្វើឱ្យសន្លាក់វិលខុសប្រក្រតី បណ្តាលឱ្យយារលីហ្គាម៉ង់ (ligament) ព័ទ្ធជុំវិញ ឱ្យឈឺចាប់ និង មិនអាចធ្វើចលនាសកម្មបាន។ ការរមួលសន្លាក់មិនទាមទារឱ្យមានការវះកាត់ទេ ប៉ុន្តែត្រូវធ្វើការព្យាបាលដោយអបសន្លាក់ និង ផ្តល់ឱសថបំបាត់ការឈឺចាប់។

**ការរលាកសាច់ដុំ**
អ. myositis
បារ. myosite (f.)

អាការៈរលាកជាលិកាសាច់ដុំដែលបណ្តាលមកពីអាំងហ្វិចស្យុង (infection) ផ្សេងៗដូចជាអាំង-ហ្វិចស្យុងដោយសារបាក់តេរីស្តាហ្វីឡូកូក (staphylocoque)។

**ការរលូតកូន**
អ. abortion
បារ. avortement (m.)

ការរបូតគភ៌ចេញពីផ្ទៃម្តាយមុន១៨០ថ្ងៃ។

ឧ. ស្ត្រីមានគភ៌ដែលបានទៅពិនិត្យផ្ទៃពោះត្រឹមត្រូវអាចចៀសផុតពីការរលូតកូន។

**ការរលូតកូនឯកឯង**
អ. spontaneous abortion
បារ. avortement spontané (m.)

ការរបូតគភ៌ចេញពីផ្ទៃម្ដាយដោយចៃដន្យនិងគ្មានការបង្ខំ។ ឧ. ការរលូតកូនឯកឯងអាចបង្កឡើងដោយសារការវិវត្តមិនត្រឹមត្រូវនៃគភ៌ សុក ឬ បង្កដោយជំងឺ ឬគ្រោះថ្នាក់របស់ម្ដាយ។

**ការរាកនោមយប់/ណុកតួរី**
អ. nocturia/ enuresis
បារ. énurèse/ nocturie (f.)

អាការៈហៀរទឹកនោមដោយមិនដឹងខ្លួន ភាគច្រើនពេលដេកលក់នៅពេលយប់។

**ការរាំងរដូវ**
អ. amenorrhea
បារ. aménorrhée (f.)

ការបាត់រដូវរបស់ស្ត្រីក្នុងវ័យបន្តពូជដែលមានលក្ខណៈមិនប្រក្រតី។ ឧ. ការមានវិបត្តិផ្លូវចិត្ត កង្វះអាហារូបត្ថម្ភ ការមានជំងឺធ្ងន់ធ្ងរប្រចាំកាយ ឬ ការមានគភ៌បង្កឱ្យស្ត្រីមានការរាំងរដូវ។

**ការរួបចូល/អាត់ដុកម្ម**
អ. adduction
បារ. adduction(f.)

ចលនាសរីរាង្គដែលទាញពីក្រៅចូលក្នុងខុសពីទម្រង់ដើម។

**ការរំលូតកូន**
អ. induced abortion
បារ. avortement (m.)

ការធ្វើឱ្យរបូតគភ៌ចេញពីផ្ទៃម្ដាយដោយចេតនា ដូចជា ការប្រើឱសថ ការបូម ឬ ការកោសគភ៌ចេញពីស្បូន។ ឱ. ក្នុងករណីស្ត្រីមានគភ៌មានជំងឺធ្ងន់ធ្ងរឬអំប្រីយ៉ុងក្នុងផ្ទៃមានលក្ខណៈមិនប្រក្រតី ដែលអាចប៉ះពាល់ដល់ជីវិតម្ដាយ គេត្រូវបង្ខំចិត្តធ្វើការរំលូតកូន។

**ការលាងរបួស/អាប់ស្ទែស្យុង**
អ. abstersion
បារ. abstersion (f.)

ការសម្អាតរបួសដោយប្រើឱសថលាងរបួស (abstergent)។

**ការស្វាប**
អ. yawning
បារ. bâillement (m.)

ការហាមាត់ដោយអចេតនាដកដង្ហើមចូលយ៉ាងខ្លាំង និងបញ្ចេញខ្យល់បន្តិចម្ដងៗមកវិញ។ សកម្មភាពនេះកើតមាននៅពេលអស់កម្លាំង ងងុយដេក ឬធុញថប់។

**ការហើមពោះ**
អ. meteorism
បារ. ballonnement/météorisme (m.)

អាការៈប៉ោងពោះដោយសារស្ទះឧស្ម័ននៅក្នុងក្រពះ ពោះវៀន។ ឱ. ជំងឺគ្រុនពោះវៀនបង្កឱ្យមានអាការៈគ្រុនក្ដៅខ្លាំង ការហើមពោះ និងរោគសញ្ញាផ្លូវរំលាយអាហារ ផ្សេងៗទៀត។

**ការអស់រដូវ/មេណូប៉ូស**
អ. menopause
បារ. ménopause (f.)

ដំណើរឈប់ធ្លាក់ឈាមរដូវរបស់ស្ត្រីដែលជាទូទៅអាចចាប់ផ្ដើមពីអាយុ៤៥ដល់៥៥ឆ្នាំ។ ឱ.ការអស់រដូវរបស់ស្ត្រីបញ្ជាក់ថាស្ត្រីនោះពុំអាចមានលទ្ធភាពបន្តពូជបានទៀតឡើយ។

**កាកស៊ីណូម** មហារីកជាលិកាភ្នាស (épithélium) ដែលគ្របលើ
អ. carcinoma សរីរាង្គណាមួយ ប៉ុន្តែមិនកាចសាហាវដូច
បារ. carcinome (m.) មីញ៉ូសាកូម (myosarcome) ទេ។

**កុងត្រាក់ទួរសាច់ដុំ** អាការៈកន្ត្រាក់សាច់ដុំយ៉ាងរឹងជាអចិន្ត្រៃយ៍ដោយ
អ. muscle contracture មូលហេតុសាច់ដុំទទួលការឈឺចាប់ ឬរំញោចយ៉ាង
បារ. contracture ខ្លាំងក្លា។
musculaire (f.)

**កូរីយ៉ុង** ស្រទាប់ក្រៅនៃភ្នាសទារក ដែលអភិវឌ្ឍទៅតាម
អ. chorion ការរីកធំធាត់របស់ទារកនៅក្នុងផ្ទៃម្ដាយ។ ឧ. អាម៉្យូស
បារ. chorion (m.) (amios) និងកូរីយ៉ុងបង្កើតបានជាភ្នាសទារក
នៅក្នុងផ្ទៃម្ដាយ។

**កោសិកា** ឯកតាទម្រង់គ្រឹះនៃជីវិតដែលជាផ្នែកតូចបំផុត
អ. cell របស់ភាវៈរស់ ហើយដែលអាចដំណើរជីវិតបាន
បារ. cellule (f.) ដោយខ្លួនឯង។ ធាតុផ្សំនៃកោសិកាមានស៊ីតូប្លាស
(cytoplasme) ណ្វៃយ៉ូ (noyau)។

**កោសិកាវិទ្យា** វិទ្យាសាស្ត្រសិក្សាពីកោសិកា (cellules) គ្រប់
អ. cytology ប្រភេទ។
បារ. cytologie (f.)

**ក្បាលបូស/គ្រាប់បូស** ដុំសរសៃៗពណ៌សនៅក្នុងបូសដែលកើតឡើងដោយសារការប្រមូលផ្តុំនៃជាលិកាស្បែកងាប់។
អ. core of boil
បារ. bourbillon ( m. )

**ក្រិនសាច់ដុំ** អាការៈក្រិនស្វិត និងរួញតូចខុសប្រក្រតីនៃសាច់ដុំ។
អ. myosclerosis
បារ. myosclérose ( f. )

**ក្រិស(ជំងឺ )/រ៉ាស៊ីទីស្ម៍** ជំងឺបណ្តាលមកពីឆ្អឹងមិនលូតលាស់ទៅតាមដំណាក់កាលនៃសរីរាង្គមនុស្ស និងសត្វដែលបណ្តាលមកពីកត្តាផ្សេងៗជាច្រើន ជាពិសេសកង្វះវីតាមីន/ជីវជាតិដេ ( vitamineD )។ ឧ. ការឱ្យទារក ឬ សត្វទទួលបានពន្លឺព្រះអាទិត្យនៅពេលព្រឹកព្រលឹមអាចជួយកាត់បន្ថយជំងឺក្រិស។
អ. rachitism
បារ. rachitisme ( m. )

**ក្រួស( វេជ្ជសាស្រ្ត )** ដុំកំណកសារធាតុកំបោរកកើតក្នុងសរីរាង្គមនុស្សសត្វ។ ឧ. ការបុកតម្រងនោមភាគច្រើនបង្កឡើងដោយសារការស្ទះក្រួសក្នុងតម្រងនោម ឬ បំពង់ទឹកនោម ( uretère )។
អ. stone/calculus
បារ. calcul ( m. )

**ក្រួសវក្កំ/ក្រួសតម្រងនោម**

អ. renalstone/ kidney stone/ renal lithiasis

បារ. calcul rénal / lithiase rénal

ដុំកំណកសារធាតុកំបោរកកើតក្នុងតម្រងនោម ដែលអាចបង្កឱ្យស្ទះប្រព័ន្ធទឹកមូត្រ និងអាចបង្កឱ្យមានអាការៈឈឺចុកចាប់។

**ក្អក**

អ. cough

បារ. toux (f.)

សញ្ញា/អាការៈបញ្ចេញខ្យល់ដោយបង្ខំរហ័សភ្លាមៗ របៀបជាកន្ត្រាក់ ឬកញ្ឆក់ និងមានសូរសំឡេងចេញពីបំពង់ក ជួនកាលកើតឡើងដោយចេតនា ឬអចេតនា និង រេផ្លិច(réflexe)។ ជាទូទៅក្អកបណ្ដាលមកពីការរលាកផ្លូវដង្ហើម និងផ្លូវរំលាយអាហារ។ ឧ. ក្មេងដែលមានជំងឺរលាកផ្លូវដង្ហើមបណ្ដាលឱ្យមានអាការៈក្អកជាញឹកញាប់។

# ខ

**ខ្ទុះតម្រងនោម/ខ្ទុះវក្កំ/ព្យោណេហ្វ្រូស**
អ. pyonephrosis/ renal empyema
បារ. pyonéphrose (f.) /empyèmerénal (m.)

អាការៈរលាកដោយមានខ្ទុះដក់ក្នុងវក្កំ (តម្រងនោម) ដែលបង្កឱ្យមានការចុកចាប់នៅចង្កេះនិងមានខ្ទុះក្នុងទឹកមូត្រ។

**ខ្ទុះបង្ហួរនោម/ប្លេណូរេ**
អ. blennorrhea
បារ. blennorrhée (f.)

អាការៈមានខ្ទុះហូរតាមបង្ហួរនោម (urètre) ដែលជារោគសញ្ញាមួយបណ្ដាលមកពីការរលាកផ្លូវទឹកមូត្រ។

# គ

**គភ៌**
អ. gestation/ pregnancy
បារ. gestation/ grossesse (f.)

កូនក្នុងផ្ទៃដែលវិវត្តពីស៊ីហ្គូត(zygote)រហូតដល់គ្រប់ខែកើត។ ឧ. ស្ត្រីរូបនេះមានគភ៌ចំនួន៥ខែមកហើយ។

**គភ៌ក្រៅស្បូន**
អ. ectopic pregnancy
បារ. grossesse ectopique/ grossesse extrautérine (f.)

គភ៌ដែលតាំងទីនៅក្នុងដៃស្បូន(trompe de fallope) កន្សោមស្បូន (ovaire) ឬធិទ្ធដ្ឋានពោះ (cavité péritonéale)។ ឧ. ស្ត្រីមានគភ៌ត្រូវទៅពិនិត្យផ្ទៃពោះឱ្យបានទៀងទាត់តាមកាលកំណត់របស់គ្រូពេទ្យឯកទេសសម្ភពដើម្បីចៀសវាងគ្រោះថ្នាក់ក្នុងករណីមានគភ៌ក្រៅស្បូន។

**គភ៌គ្រប់ខែ**
អ. pregnancy in term
បារ. grossesse à terme (f.)

គភ៌ដែលមានអាយុជាមធ្យម៩ខែ១០ថ្ងៃរាប់ចាប់ពីថ្ងៃបាត់រដូវរហូតដល់ថ្ងៃសម្រាល។ ឧ. គភ៌គ្រប់ខែអាចលើស ឬខ្វះ២សប្តាហ៍នៃអាយុរបស់គភ៌។

**គីមីព្យាបាល**
អ. chemotherapy
បារ. chimiothérapie (f.)

វិធីសាស្ត្រព្យាបាលជំងឺដោយការប្រើសារធាតុគីមី។

**គភ៌ចាស់ខែ**
អ. prolonged pregnancy/ postterm pregnancy
បារ. grossesse prolongée (f.)

គភ៌ដែលមានអាយុលើសពី៤២សប្តាហ៍ គឺមានរយៈពេលវែងជាងគភ៌គ្រប់ខែធម្មតា។ ឧ. ស្ត្រីមានគភ៌ចាស់ខែចាំបាច់ត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យឯកទេសសម្ភពដើម្បីចៀសវាងគ្រោះថ្នាក់នៅពេលសម្រាល។

**គីស្ត**
អ. cyst
បារ. kyste (m.)

ដុំពកបេនីញ (tumeur bénigne) ជាសារធាតុរាវរុំពទ្ធជុំវិញដោយស្រោម ដែលគ្មានទំនាក់ទំនងនឹងជាលិកាខាងក្រៅ។ ឧ. គីស្តអាចកើតមាននៅគ្រប់សរីរាង្គទាំងអស់ដែលទាមទារឱ្យអ្នកជំងឺត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យវះកាត់។

**គ្រុន**
អ. fever/pyrexia
បារ. fièvre/pyrexie (f.)

អាការៈបណ្តាលឱ្យកម្តៅក្នុងខ្លួនកើនឡើងហួសប្រក្រតី។ ឧ. ក្មេងដែលម្តាយនាំទៅមន្ទីរពេទ្យបង្អែកនេះ កំពុងមានជំងឺគ្រុនក្តៅ។

**គ្រោងឆ្អឹង/ អដ្ឋិសង្ខលិក**
អ. skeleton
បារ. squelette (m.)

សំណុំឆ្អឹងទាំងអស់នៃសពាង្គកាយដែលបង្កើតបានជារចនាសម្ព័ន្ធនិងរាងពៅរបស់មនុស្សនិងសត្វ។ ឧ. អដ្ឋិសង្ខលិករបស់មនុស្សមានឆ្អឹងចំនួន២០៦ ដែលរួមមានឆ្អឹងវែង ឆ្អឹងសំប៉ែត និងឆ្អឹងខ្លី។

**គ្រោះថ្នាក់**
អ. accident
បារ. accident (m.)

ហេតុការណ៍ជាវិបត្តិដែលកើតឡើងបន្ទាន់ឬដោយចៃដន្យ។ ឧ. ក្នុងករណីសម្ពាធឈាមឡើងខ្ពស់ អ្នកជំងឺអាចមានគ្រោះថ្នាក់សរសៃឈាមក្នុងខួរក្បាល (accident vasulaire cérébral AVC)។

**គ្លុយស៊ីដ**
អ. glucid
បារ. glucide (m.)

សារធាតុស្ករជាកាបោនអ៊ីដ្រាត (hydrate de carbone) ដែលក្នុងនោះមានស្ករទោល (ose sucre simple) និង ស្ករកុំផ្លិច (oside sucre complexe)។

**គំនាំងបេះដូង/ ប្លុកបេះដូង**
អ. heart block
បារ.bloc cardiaque

វិបត្តិនៃចង្វាក់បេះដូងរហូតដល់គាំងដោយសារដាច់រលករំញោច (onde d'excitation) បញ្ជាសាច់ដុំបេះដូងបណ្ដាលមកពីការប្រើប្រាស់ឱសថខុស ឬ សារធាតុពុល ...។

**គំនាំងសន្លាក់/ អង់គីឡូស**
អ. ankylosis/ (joint) stiffness
បារ. ankylose (f.)

អាការៈគាំងសន្លាក់ពុំអាចធ្វើចលនាសកម្ម ឬ អកម្ម បានបង្កដោយសាច់ដុំ ឬ ពួរសាច់ដុំនៃសន្លាក់នោះក្រិនរឹង ឬ ដោយមូលហេតុរលាករលួយសន្លាក់។

# ច

**ចលនាព្យាបាល/ គីណេព្យាបាល**
អ. kinesitherapy
បារ.kinésithérapie (f.)/ cinésithérapie(f.)

វិធីសាស្ត្រព្យាបាលជំងឺដោយហត្ថចលនាដើម្បីរំញោចសរីរាង្គ ដូចជាការច្របាច់ ការចុច... ឬប្រើឧបករណ៍ផ្សេងៗ។ កន្លងមកគេធ្លាប់ប្រើពាក្យនេះថាការព្យាបាលដោយចលនា។

**ចិត្តព្យាបាល**
អ. psychotherapy
បារ. psychothérapie (f.)/traitement psychique (m.)

វិធីសាស្ត្រព្យាបាលជំងឺដោយការអប់រំសម្រួលផ្លូវចិត្តក្នុងគោលបំណងបន្ធូរអារម្មណ៍អ្នកជំងឺ។

**ចូល**
អ. afferent
បារ. afférent(adj.)

ដែលនាំសារធាតុអ្វីមួយចូលទៅក្នុងសរីរាង្គ។

**ចេញ**
អ. efferent
បារ. efférent(adj.)

ដែលនាំសារធាតុអ្វីមួយចេញពីសរីរាង្គទៅក្រៅ។

# ជ

**ជាលិកា** សំណុំកោសិកា ដែលមានទម្រង់រចនាសម្ព័ន្ធ និង
អ. tissue មុខងារដូចគ្នាបង្កើតបានជាសរីរាង្គមួយ ឬផ្នែក
បារ. tissu (m.) មួយនៃសរីរាង្គ។

**ជាលិកាវិទ្យា** វិទ្យាសាស្ត្រសិក្សាពីជាលិកា (tissus) គ្រប់
អ. histology ប្រភេទ។
បារ. histologie (f.)

**ជីវគីមីវិទ្យា** វិទ្យាសាស្ត្រសិក្សាអំពីសមាសធាតុ និងប្រតិកម្ម
អ. biochemistry គីមីក្នុងភាវៈមានជីវិត។ ឧ. ការសិក្សាលម្អិតពី
បារ. biochimie (f.) ការរំលាយអាហារនៅក្នុងខ្លួនមនុស្សសត្វជាផ្នែក
មួយនៃជីវគីមីវិទ្យា។

**ជីវវិទ្យា** វិទ្យាសាស្ត្រសិក្សាអំពីភាវៈមានជីវិត (មនុស្ស សត្វ
អ. biology និង រុក្ខជាតិ)។
បារ. biologie (f.)

**ជំងឺក្រិន** សភាពរឹងឬក្រាស់នៃជាលិកា ឬសរីរាង្គណាមួយ
អ. sclerosis ដែលបណ្ដាលឱ្យបាត់បង់មុខងាររបស់វា។
បារ. sclérose (f.) ឧ. ការពិសាស្រាជាកត្តាមួយជំរុញឱ្យជំងឺរលាក
ថ្លើមវិវត្តទៅជាជំងឺក្រិនថ្លើម។

**ជំងឺក្រិនថ្លើម/ សៀរ៉ូសថ្លើម**
អ. hepatic cirrhosis
បារ. cirrhose du foie/ cirrhose hépatique (f.)

ជំងឺថ្លើមម្យ៉ាង បណ្ដាលមកពីការរលាកកោសិកា (cellule) ថ្លើមធ្វើឱ្យជាលិកា (tissu) ថ្លើមរឹងក្រិនលែងបំពេញមុខងារបាន។ ឧ. ការព្យាបាលជំងឺរលាកថ្លើមទាន់ពេលវេលាអាចទប់ស្កាត់ការវិវត្តទៅជាជំងឺក្រិនថ្លើមបាន។

**ជំងឺខ្វាក់មាន់**
អ. hemeralopia/ night blindness
បារ. héméralopie (f.)

ជំងឺមួយប្រភេទច្រើនកើតលើកុមារ ដែលភ្នែកមើលមិនឃើញខុសប្រក្រតីនៅទីងងឹតនៅពេលយប់ ឬនៅពេលមានពន្លឺខ្សោយ។ ជាទូទៅជំងឺនេះកើតឡើងដោយសារកង្វះវីតាមីនអា/ជីវជាតិអា (vitamineA)។ ឧ. ជំងឺខ្វាក់មាន់អាចបង្ការ និងព្យាបាលដោយឱសថឬអាហារដែលសម្បូរជីវជាតិអា។

**ជំងឺជ្រាំង**
អ. thrush
បារ. muguet (m.)

ជំងឺមួយប្រភេទ ដែលកើតឡើងជាផ្លាកស្នាម (taches) ពណ៌សស្រអាប់ទំហំតូច ឬ ធំនៅលើភ្នាសក្នុងមាត់ និងជួនកាលរលាកដល់ដើមបំពង់កដែលបង្កឡើងដោយផ្សិតកង់ឌីដាអាប៊ីកង់ (candida albicans)។ ជំងឺនេះច្រើនកើតនៅលើកុមារ។ ឧ.ផលវិបាកនៃជំងឺជ្រាំងបណ្ដាលឱ្យខ្វះអាហារូបត្ថម្ភ។

**ជំងឺធូលីសួត/ផ្នឹម៉ូកូនីញ៉ូស**
អ. pneumoconiosis
បារ. pneumoconiose (f.)

ជំងឺសួតរ៉ាំរ៉ៃម៉្យាង ដែលបង្កដោយកំណកធូលី (ផង់សារធាតុរ៉ែ ឬ សារធាតុគីមី...) នៅក្នុងសួត តាមការដកដង្ហើមស្រូបចូលក្នុងរយៈពេលយូរ។

**ជំងឺប្រគ្រីវ/ហ្គុត**
អ. gout
បារ. goutte (f.)

ជំងឺបង្កឱ្យឈឺចុកចាប់ ជាពិសេសនៅពេលយប់ ពេលសម្រាក ឬ គ្មានសកម្មភាពនៅត្រង់សន្លាក់ម្រាមដៃ ម្រាមជើង និងបណ្ដាសន្លាក់ដទៃទៀត។ ជំងឺនេះច្រើន បណ្ដាលមកពីសារធាតុអាស៊ីតអ៊ុយរិក (acide urique) មានកម្រិតខ្ពស់ហួសប្រក្រតី។

ឧ. គ្រូពេទ្យបានឱ្យដំបូន្មានដល់អ្នកជំងឺប្រគ្រីវនេះ ឱ្យតមចំណីអាហារណាដែលបង្កឱ្យកើនសារធាតុអាស៊ីតអ៊ុយរិក ដូចជាសាច់អាំង គ្រឿងសមុទ្រ គ្រឿងក្នុងជ្រូកមាន់ទា,...។

**ជំងឺផ្សិត/មីកូស**
អ. mycosis
បារ. mycose (f)

ជំងឺដែលបង្កឡើងដោយមេរោគជាពពួកផ្សិត (champignon)។

**ជំងឺពកក/**
**ជំងឺពកទៀរ៉ូអ៊ីត**
អ. goiter/goitre
បារ. goitre ( f. )

ជំងឺដែលសម្គាល់ដោយការរីកធំ ឬ មានដុំពកនៃក្រពេញទីរ៉ូអ៊ីត( la glande thyroïde) នៅនឹង ក ដោយសារក្រពេញនេះផលិតអ័រម៉ូនតិចពេក ឬ ច្រើនពេក។ ជំងឺពកកជាធម្មតាច្រើនតែបណ្តាលមកពីកង្វះជាតិអ៊ីយ៉ូតនៅក្នុងចំណីអាហារ។ គេសង្កេតឃើញជំងឺពកកមានច្រើនសណ្ឋាន។ ឧ.អ្នកបរិភោគអំបិលមានសារជាតុអ៊ីយ៉ូតអាចការពារមិនឱ្យកើតជំងឺពកកបាន។

**ជំងឺពកឆ្អឹង/អូស្តេអូម**
អ. osteoma
បារ. ostéome ( f. )

ជំងឺមួយប្រភេទដែលមានអាការៈពីរយ៉ាងគឺ ១- អាការៈរីកលូតលាស់ខុសប្រក្រតីរបស់ជាលិកាឆ្អឹងពេញវ័យដែលវិវត្តយឺតៗនៅនឹងកន្លែងបង្កបានជាកំពកនៃឆ្អឹង។ ២- អាការៈជាដុំពកមាន លក្ខណៈជាឆ្អឹងដែលកកើតឡើងនៅកន្លែងប៉ះទង្គិចញ៉ើក-ញាប់នៃជាលិកាទន់ របស់សព៌ាង្គកាយ។ ឧ. ជំងឺពកឆ្អឹងត្រូវតែព្យាបាលដោយការវះកាត់។

**ជំងឺពុកឆ្អឹង/**
**អូស្តេអូប៉ូរ៉ូស**
អ. osteoporosis
បារ. ostéoporose ( f. )

ជំងឺមួយប្រភេទដែលកើតឡើងដោយសារកង្វះសារធាតុរ៉ែ និងការថយចុះនៃបណ្តាញប្រព័ន្ធប្រូតេអ៊ីនរបស់ឆ្អឹង។ ជំងឺនេះបណ្តាលឱ្យមានការឈឺចុកចាប់ការខូចទម្រង់ដើមនៃឆ្អឹងនិងធ្វើឱ្យឆ្អឹងងាយបាក់។ ឧ.ជំងឺពុកឆ្អឹងជាជំងឺដែលច្រើនកើតលើស្ត្រីវ័យចាស់។

**ជំងឺភ្នែកក្រហម**
អ. conjunctivitis
បារ. conjonctivite (f.)

ជំងឺមួយប្រភេទដែលបង្កឱ្យរលាកភ្នាសក្នុងត្របកភ្នែក និង គ្រាប់ភ្នែកលើកលែងតែកែវភ្នែក (គ័រណេ= cornée)។ មូលហេតុបណ្ដាលមកពីការបង្ករោគដោយមីក្រុប ចំណាំងពន្លឺខ្លាំង ឬ អង្គធាតុក្រៅ (corps étranger) ចូលក្នុងភ្នែក។ ឧ. ការលាងដៃដោយសាប៊ូជាប្រចាំកាត់បន្ថយការកើតជំងឺភ្នែកក្រហម។

**ជំងឺមហារីក**
អ. cancer
បារ. cancer (m.)

ជំងឺកើតឡើង ជាដុំពក ជាដំបៅមិនប្រក្រតីនៅតាមសរីរាង្គណាមួយរបស់មនុស្សឬសត្វបង្កឡើងដោយកោសិកា ដែលដុះរីកលូតលាស់ខុសធម្មតា និង រាលដាលបង្កជាជំងឺស្រួចស្រាល់ ឬរ៉ាំរ៉ៃបណ្ដាលឱ្យស្លាប់បើមិនមានការព្យាបាលឱ្យបានត្រឹមត្រូវតាមក្បួនខ្នាតជំនាញឱ្យទាន់ពេលវេលាទេនោះ។ ឧ. អ្នកជំងឺនេះស្លាប់ដោយជំងឺមហារីកថ្លើម។

**ជំងឺរលាកខួរឆ្អឹង/ អូស្តេអូមីយេលីត**
អ. osteomyelitis
បារ. ostéomyélite (f.)

ជំងឺមួយប្រភេទដែលកើតឡើងដោយការរលាកព្រមគ្នាទាំងតួឆ្អឹង ទាំងខួរឆ្អឹងដោយមូលហេតុច្រើនយ៉ាង។ ឧ. ជាទូទៅជំងឺរលាកខួរឆ្អឹងស្រួចស្រាល់ច្រើនកើតមាននៅលើកុមារ។

**ជំងឺរលាកឆ្អឹង/អូស្តេអ៊ីត**
អ. osteitis
បារ. ostéite ( f. )

អាការៈមួយប្រភេទដែលកើតពីការរលាកតួឆ្អឹង។ ឧ. ជាទូទៅមូលហេតុដែលបង្កឱ្យមានជំងឺរលាកឆ្អឹងបណ្ដាលមកពីបាក់តេរី។

**ជំងឺរលាកទឹកសន្លាក់/ស៊ីណូវីត**
អ. synovitis
បារ. synovite ( f. )

ជំងឺរលាកទឹកសន្លាក់មានសភាពស្រួចស្រាល់ ឬរ៉ាំរ៉ៃដែលធ្វើឱ្យស្ងួត ឬ មានសារធាតុរាវមិនប្រក្រតីដូចជាឈាម ទឹករងៃ ឬ អាចមានខ្ទុះ។ ឧ. បើអ្នកជំងឺសង្ស័យថាខ្លួនមានជំងឺរលាកទឹកសន្លាក់ត្រូវទៅពិគ្រោះជាមួយនឹងគ្រូពេទ្យឯកទេសចៀសវាងការប្រើថ្នាំដោយខ្លួនឯង។

**ជំងឺរលាកពហុសន្លាក់/ប៉ូលីអាទ្រីត**
អ. polyarthritis
បារ. polyarthrite ( f. )

ជំងឺមួយប្រភេទដែលកើតឡើងពីការរលាកស្រួចស្រាល់ ឬ រ៉ាំរ៉ៃក្នុងសន្លាក់ជាច្រើនព្រមៗគ្នា។ ឧ. ជំងឺរលាកពហុសន្លាក់ជារោគសញ្ញានៃជំងឺគ្រុនសន្លាក់ ( rhumatisme ) ស្រួចស្រាល់និងរ៉ាំរ៉ៃ។

**ជំងឺរលាកមាត់**
អ. stomatitis
បារ. stomatite ( f. )

ជំងឺរលាកភ្នាសសើមក្នុងមាត់បង្កដោយបាក់តេរី វីរុស ពពួកផ្សិត,...។ ឧ. កង្វះអនាម័យមាត់ធ្មេញជាកត្តាបណ្ដាលឱ្យកើតជំងឺរលាកមាត់។

**ជំងឺរលាកសន្លាក់**
អ. arthritis
បារ. arthrite (f.)

អាការៈរលាកនៅត្រង់សន្លាក់បណ្ដាលឱ្យឡើងក្រហមក្ដៅ ឈឺចាប់ និង ហើម ដែលមានលក្ខណៈស្រួចស្រាល់ឬរ៉ាំរ៉ៃ។ ឧ. អ្នកជំងឺរលាកសន្លាក់គប្បីទៅពិនិត្យព្យាបាលតាមការណែនាំរបស់គ្រូពេទ្យឯកទេស។

**ជំងឺរលាកសរសៃពួរសាច់ដុំ/ ជំងឺរលាកតង់ដុង**
អ. tendinitis
បារ. tendinite/ ténosite (f.)

ជំងឺបណ្ដាលមកពីរលាកសរសៃពួរដែលភ្ជាប់សាច់ដុំទៅនឹងឆ្អឹង។

**ជំងឺរលាកអណ្ដាត**
អ. glossitis
បារ. glossite (f.)

ជំងឺមួយប្រភេទដែលបង្កឱ្យរលាកភ្នាសអណ្ដាតសើៗឬជ្រៅ និង មានលក្ខណៈស្រួចស្រាល់ ឬរ៉ាំរ៉ៃ។ ឧ. អ្នកជំងឺរលាកអណ្ដាតមានអាការៈហៀរទឹកមាត់ជាប្រចាំ។

**ជំងឺរាក**
អ. diarrhea/diarrhoea
បារ. diarrhée(f.)

ជំងឺ ដែលបណ្ដាលឱ្យមានការបន្ទោបង់លាមកមានសភាពរាវ និងញឹកញាប់។ ឧ. នៅមន្ទីរពិសោធន៍បាក់តេរីសាស្ត្រ (laboratoire bactériologique) នេះ គេកំពុងវិភាគលាមករបស់អ្នកជំងឺរាកដើម្បីរកមេរោគដែលបង្កឱ្យរាក។

**ជំងឺវិទ្យា/ប៉ាតូវិទ្យា** វិទ្យាសាស្ត្រសិក្សាអំពីជំងឺគ្រប់ប្រភេទដើម្បីរកមូលហេតុរោគវិនិច្ឆ័យនិងវិធីព្យាបាល។
អ. pathology
បារ. pathologie(f.)

**ជំងឺសន្លាក់** ជំងឺគ្រប់ប្រភេទដែលកើតឡើងនៅក្នុងសន្លាក់។ ឧ. អាការៈគាំងសន្លាក់ជាផលវិបាកនៃជំងឺសន្លាក់។
អ. arthropathy
បារ. arthropathie (f.)

**ជំងឺសាច់ដុំ** ជំងឺគ្រប់ប្រភេទនៃប្រព័ន្ធសាច់ដុំ។
អ. myopathy/myopathia
បារ. myopathie (f.)

**ជំងឺហឺត** ជំងឺកើតឡើងនៅផ្លូវដង្ហើមបណ្តាលឱ្យអ្នកជំងឺមានការលំបាកក្នុងការដកដង្ហើមហត់ដង្ហក់។ ជំងឺនេះបណ្តាលមកពីមូលហេតុច្រើនយ៉ាង។ អ្នកជំងឺអាចស្លាប់បើពុំមានការព្យាបាលត្រឹមត្រូវទាន់ពេលវេលានោះទេ។ ឧ. ដើម្បីចៀសវាងជំងឺហឺតគួររស់នៅក្នុងបរិយាកាសល្អ អនាម័យល្អ និងចៀសវាងការប្រើថ្នាំដោយគ្មានវេជ្ជបញ្ជា។
អ. asthma
បារ. asthme (m.)

**ជំនាប់ស្អិត/អាដេរ៉ង់** អាការៈស្អិតជាប់គ្នារវាងសរីរាង្គពីរ ឬ ច្រើននៅក្នុងកន្លែងណាមួយនៃសព៌ាង្គកាយដោយមូលហេតុផ្សេងៗ។ ឧ. អស់រយៈពេលយូរក្រោយពីការវះ
អ. adhesion
បារ. adhérence (f.)

កាត់ក្នុងពោះ ករណីខ្លះអាចកើតមានជំនាប់ស្អិតនៃពោះវៀន។

**ជំនួយកម្លាំង/អាណាឡិបស៊ី**

អ. analepsia / analepsis

បារ. analepsie ( f. )

វិធីធ្វើឱ្យអ្នកជំងឺមានកម្លាំងពលំឡើងវិញ ក្រោយពេលជាសះស្បើយ។

# ឈឺ

**ឈាមខន់/**
**កំណកឈាម**
អ. blood clot
បារ.caillot sanguin

ដុំឈាមដែលបានមកពីការកកសម្រាប់បិទសរសៃឈាមដាច់ ឬ របួស និង បញ្ឈប់លំហូរឈាម។

**ឈឺ**
អ. ache
បារ. mal ( m. )

អាការៈមិនស្រួលនៃសរីរាង្គណាមួយ។

**ឈឺក្បាល**
អ. cephalalgia/
cephalgia/
cephalodynia/
headache
បារ. céphalalgie/
céphalée ( f )/
mal de tête

អាការៈដែលឈឺចាប់ក្នុងក្បាលបណ្តាលមកពីមូលហេតុច្រើនយ៉ាង ពេលខ្លះមិនអាចរកមូលហេតុឃើញឡើយ។ ឧ. ការសម្រាកគ្រប់គ្រាន់ និង ទៀងទាត់ពេលវេលាអាចជួយបន្ថយអាការៈឈឺក្បាល។

# ដ

**ដុំពក/ទុយម័រ**
អ. tumor
បារ. tumeur (f.), néoplasme (m.)

ការដុះសាច់មិនប្រក្រតីនៃជាលិកាផ្សេងៗរបស់សរីរាង្គ។ ឧ. អ្នកជំងឺដែលមានដុំពកត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យសល្យសាស្ត្រ (chirurgien)។

**ដុំពកក្រពេញ/អាដេណូម**
អ. adenoma
បារ. adénome (m.)

ដុំពកបេនីញនៃក្រពេញណាមួយដែលមានរចនាសម្ព័ន្ធដូចក្រពេញនោះ និងមានស្រោមរុំព័ទ្ធយ៉ាងមាំ ហើយមានសកម្មភាពសេក្រេស្យុង (sécrétion) ខ្លាំងក្លាជាងធម្មតា។ ឧ. អាដេណូមក្រពេញទីរ៉ូអ៊ីដ (thyroïde) ដែលមានសេក្រេស្យុងអ័រម៉ូនទីរ៉ុកស៊ីន (thyroxine) ច្រើនលើសធម្មតាតម្រូវឱ្យមានការវះកាត់យកចេញ។

**ដុំពកខ្លាញ់/លីប៉ូម**
អ. lipoma
បារ. lipome (m.)

ដុំពកបេនីញនៃជាលិកាខ្លាញ់មានស្រោមរុំពទ្ធជុំវិញដែលគ្មានទំនាក់ទំនងនឹងជាលិកាខាងក្រៅ។ ឧ. លីប៉ូមជាដុំពកដែលងាយស្រួលធ្វើរោគវិនិច្ឆ័យ និង ព្យាបាល ប៉ុន្តែវាអាចវិវត្តទៅជាជំងឺមហារីកដុំខ្លាញ់។

**ដុំពកបេនីញ/ទុយម័របេនីញ**
អ. benign tumor
បារ. tumeur bénigne

ការដុះសាច់មិនប្រក្រតីនៃជាលិកាជាដុំពកស្លូតដែលពុំទាន់មានលក្ខណៈកាចសាហាវ។

ឧ. ដុំពកខ្លាញ់ធម្មតាអាចជាដុំពកបេនីញ ប៉ុន្តែដើម្បីសុវត្ថិភាព អ្នកជំងឺត្រូវទៅពិគ្រោះជាមួយនឹងគ្រូពេទ្យវះកាត់។

**ដុំពកភ្នាស**
អ. epithelioma
បារ. épithéliome/ épithélioma (m.)

ដុំពកកាច (tumeur maligne) កើតឡើងពីជាលិកាភ្នាស(tissu d'épithélium) មិនប្រក្រតីរបស់សរីរាង្គដែលជាមហារីក។

**ដុំពកម៉ាលីញ/ទុយម័រម៉ាលីញ**
អ. malign tumor
បារ. tumeur maligne

ការដុះសាច់មិនប្រក្រតីនៃជាលិកាជាដុំពកកាចដែលមានលក្ខណៈកាចសាហាវ ដែលជាជំងឺមហារីក (cancer)។ ដុំពកម៉ាលីញអាចកើតនៅគ្រប់សរីរាង្គទាំងអស់នៃសព៌ាង្គកាយ។

**ដុំពកវិទ្យា/អុងកូវិទ្យា**
អ. oncology
បារ. oncologie (f.)

វិទ្យាសាស្ត្រសិក្សាពីដុំពក (tumeurs) នៃជាលិកា (tissus)ផ្សេងៗរបស់សរីរាង្គ។

**ដុំពកសរសៃឡាំហ្វ៍/ឡាំហ្វង់ហ្សីយ៉ូម**
អ. lymphangioma
បារ. lymphangiome (m.)

អង់ហ្ស៊ីយ៉ូម(angiome)នៃសរសៃឡាំហ្វ៍ (vaisseau lymphatique)មានលក្ខណៈហើមទន់ជ្រាយ ដែលច្រើនកើតនៅថ្នក់ខាងលើឆ្អឹងដងកាំបិត។

**ដំណុះធ្មេញ**
អ. eruption of tooth
បារ. éruption dentaire

ការដុះធ្មេញដែលពកចេញពីអញ្ចាញ។ ឧ. កុមារមានដំណុះធ្មេញពីរលើកគឺធ្មេញទឹកដោះ( dent de lait) និងធ្មេញអចិន្ត្រៃយ៍( dent parmanente )។

**ដំណួចស្បែក**
អ. skin rash
បារ. rash cutané

កន្ទួលតូចៗនៅលើស្បែក ដែលមិនស្ថិតស្ថេរជួនកាល រមាស់ និង/ឬ ដែលបណ្តាលឱ្យមានអាការៈគ្រុនក្តៅ។ ឧ. ប្រតិកម្មឱសថមួយចំនួនអាចបណ្តាលឱ្យមានដំណួចស្បែក។

**ដំណើរជ្រុះរោម/អាឡូប៉េស៊ី**
អ. alopecia
បារ. alopécie ( f. )

អាការៈជ្រុះរោម សក់ខ្លះៗឬអស់រលីងនៅផ្នែកណាមួយនៃសព៌ាង្គកាយ។

**ដំណើរមានរដូវ**
អ. menstruation
បារ. menstruation ( f )

ដំណើរហូរឈាមពីស្បូនរបស់ស្ត្រីមានរយៈពេលធម្មតាពី៣ទៅ៧ថ្ងៃតាមវដ្តរដូវ( cycle menstruel )។

**ដំបៅងា**
អ. yaws
បារ. pian/buba/boubas ( m. )

ជំងឺឆ្លងមួយប្រភេទរាតត្បាតនៅតំបន់ត្រូពិកដោយសារ មេរោគស្ពៀរ៉ូកែត (spirochète) ឈ្មោះត្រេប៉ូណេម៉ាពែតឺនុយ (treponema pertenue)។ អ្នកជំងឺមានអាការៈក្តៅខ្លួន ឈឺចុកចាប់អវយវៈបន្ទាប់មកមានចេញជាដំបៅពងបែករលួយ

រហូតដល់ដាលិកាក្រោមស្បែកជាពិសេសនៅលើ
មុខ ដៃ និង ជើង។ ៥. ដំបៅងាអាចឆ្លងតាមរយៈ
ការប៉ះពាល់ដោយផ្ទាល់លើដំបៅរបស់អ្នកជំងឺ។

# ណោ

**ណូឌុល** ដុំពកបេនីញនៃជាលិកាដែលមានរាងមូលតូចៗ ក្រឡាប់ចុះឡើងនៅពេលយើងស្ទាបជាពិសេស ដុំពក បេនីញនៃជាលិកាក្រពេញឡាំហ្វ៍ ( glande lymphatique )។
អ. nodule
បារ. nodule ( m. )

# ត

**តិរច្ឆានភាព/ បេស្យាលីតេ**
អ. bestiality
បារ. bestialité (f.)

ការរួមភេទរវាងមនុស្សជាមួយនឹងសត្វ។

**តុកស៊ីកូវិទ្យា/វិសវិទ្យា**
អ. toxicology
បារ. toxicologie (f.)

វិទ្យាសាស្ត្រសិក្សាអំពីជាតុពុល។ ឧ.តុកស៊ីកូវិទ្យា/វិសវិទ្យាជាមុខវិជ្ជាមួយនៅក្នុងកម្មវិធីសិក្សាផ្នែកវេជ្ជសាស្ត្រ។

**តុកស៊ីន/វិសជាតុ**
អ. toxin
បារ. toxine (f.)

សារជាតុដែលកកើតឡើងពីមីក្រូសរពាង្គកាយ ហើយបណ្តាលឱ្យមានជំងឺ។ តុកស៊ីនមានដើមកំណើតចេញពីប្រភពពីរ :

-ចេញពីជីវាណូ ឬ ខ្ទមេរោគមួយ(germe) ដែលបង្កឱ្យមានជំងឺ។

- ចេញពីពួកផ្សិតពុល ឬ ពីពិសរបស់សត្វល្អិត និងសត្វពស់ដែលមិនមែនជាមីក្រុប។

**តុល្យភាព**
អ. balance
បារ. balance (f.)

ស្ថានភាពលំនឹងរវាងជាតុនានានៅក្នុងភាវៈរស់ដូចជាលំនឹងអត្រាអេឡិចត្រូលីត(électrolyte) អាស៊ីដបាស(acidebase)។

**ត្រូម៉ា** របួសធ្ងន់ធ្ងរខាងផ្លូវកាយឬផ្លូវចិត្តដែលបង្កដោយគ្រោះថ្នាក់ឬវិបត្តិផ្សេងៗ។
អ. trauma
បារ. trauma ( m. )

**ត្រូម៉ាតូវិទ្យា** វិទ្យាសាស្ត្រសិក្សាអំពីមូលហេតុ រោគវិនិច្ឆ័យ និង វិធីព្យាបាលរបួសផ្លូវកាយ ឬ ផ្លូវចិត្តគ្រប់ប្រភេទ។
អ. traumatology
បារ. traumatologie ( f. )

**ត្រូម៉ាទីស្ម** ភាពគ្រាំគ្រាផ្លូវកាយ ឬ ផ្លូវចិត្តដែលបង្កឡើង ដោយគ្រោះថ្នាក់ ឬ វិបត្តិធ្ងន់ធ្ងររ៉ាំរ៉ៃផ្សេងៗ។
អ. traumatism
បារ. traumatisme ( m. )

**តំណឹងចិត្ត/អង់ហ្គួស** អាការៈទង្គឹះចិត្ត តានតឹងនិងថប់អារម្មណ៍ធ្ងន់ធ្ងរ ដែលប៉ះពាល់រហូតដល់ប្រព័ន្ធឈាមរត់ ប្រព័ន្ធផ្លូវដង្ហើម...។
អ. anguish
បារ. angoisse ( f. )

# ថ

**ថង់** បរិក្ខារវេជ្ជសាស្ត្រជាស្បោងម្យ៉ាងសម្រាប់ត្រង លំហូរសារធាតុរាវ ខ្ទុះ ឬ លាមកដែលហូរចេញពីសព៌ាង្គកាយ។

អ. sac/bag

បារ. sac ( m. )

**ថប់អារម្មណ៍** អាការៈតប់ប្រមល់ផ្លូវចិត្តរហូតដល់បេះដូងដើរញាប់ និងបែកញើស។

អ. anxiety

បារ. anxiété ( f. )

**ថ្នាលវប្បកម្ម** ប៊ូយ៉ុងឬថ្នាលសម្រាប់បណ្ដុះនិងចិញ្ចឹមបាក់តេរី។

អ. culture medium

បារ. bouillon de culture

# ទ

**ទងសុក/ទងផ្ចិត**
អ. umbilical cord
បារ. cordon ombilical (m.)

អន្តរសរីរាង្គមានសណ្ឋានប្រហាក់ប្រហែលខ្សែពួរដែលតភ្ជាប់ពីផ្ចិតទារកទៅសុក។ នៅក្នុងទងសុកមានសរសៃឈាមពីរបែប មួយជាអាកទែ (artère) នាំឈាមពីសុកទៅទារក និងមួយទៀតជាវ៉ែន (veine) នាំឈាមពីទារកទៅសុកវិញ។ នៅក្រោយពេលទារកប្រសូតចេញពីផ្ទៃម្ដាយ ឆ្មបត្រូវកាត់ផ្ដាច់ទងសុកជាចាំបាច់។

**ទល់លាមក**
អ. constipation/ costiveness
បារ. constipation (f.)

ដំណើរបន្ទោបង់លាមកមិនប្រក្រតី គឺមានការយឺតការជុះមិនចេញ លាមកមានសភាពរឹងបណ្ដាលមកពីមូលហេតុផ្សេងៗបង្កឡើង។ ឧ. ដើម្បីចៀសវាងទល់លាមកគួរគប្បីបរិភោគបន្លែ ផ្លែឈើ និងទឹកឱ្យបានច្រើន។

**ទារកក្នុងផ្ទៃ**
អ. fetus
បារ. fœtus (m.)

គភ៌ដែលមានអាយុក្នុងរយៈពេលចាប់ពីខែទី៤រហូតដល់ពេលសម្រាល។ ឧ. ចំពោះស្ត្រីដែលមានគភ៌ចាប់ពីអាយុ៤ខែឡើងទៅ ទារកក្នុងផ្ទៃចាប់ផ្ដើមកម្រើក។

**ទារកមិនគ្រប់ខែ**

អ. premature infant

បារ. enfant prématuré

ទារកមានជីវិតធម្មតាដែលកើតមុនរយៈពេល៣៧សប្តាហ៍ហើយមានទម្ងន់ក្រោម២២០០ក្រាម។ ទារកមិនគ្រប់ខែត្រូវតែទទួលការចិញ្ចឹមដោយសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យឯកទេស។

**ទឹកកាម**

អ. sperm/semen

បារ. sperme ( m. )

សារធាតុខាប់ពណ៌សដែលផលិតចេញពីសរីរាង្គបន្តពូជរបស់មនុស្សប្រុស ឬសត្វឈ្មោល។ សារធាតុនេះមានសេរ៉ូមប្លាស្មា និងស្ពែម៉ាតូសូអ៊ីត (spermatozoïde )។

**ទឹកដោះដំបូង**

អ. colostrum/ neogala /protogala

បារ. colostrum ( m. )

ទឹកដោះចេញក្រោយពីការសម្រាលកូនរួចរយៈពេលតែពីរឬបីថ្ងៃប៉ុណ្ណោះចំពោះមនុស្ស តែចំពោះសត្វរយៈពេលអាចខ្លី ឬ វែងជាងនេះ។ ទឹកដោះនេះមានពណ៌លឿង សម្បូរដោយសារជាតិប្រូតេអ៊ីនជាពិសេសអាល់ប៊ុយមីនដែលមានតួនាទីទប់ស្កាត់ជំងឺរលាកក្រពះ ពោះវៀន បន្សាត់អាចម៍ព្រៃ និងនាំអង់ទីករ(anticorps)ពីម្តាយទៅកូន។ ឧ. ម្តាយក្រោយពីការសម្រាលកូនចាំបាច់ត្រូវបំបៅកូនភ្លាមដោយទឹកដោះដំបូង។

**ទឹកប្រមាត់**　　វត្ថុរាវអាល់កាទ្បាំងពណ៌លឿងបៃតងមានរសជាតិល្វីងដែលបញ្ចេញដោយថ្លើមសម្រាប់បន្សាបអាសុីដក្នុងអាហារនៅដើមពោះវៀនតូច។

អ. bile
បារ. bile (f.)

**ទឹកភ្លោះ**　　សារធាតុរាវដែលនៅជុំវិញទារកក្នុងផ្ទៃម្តាយ។ ទឹកភ្លោះមានមុខងារជួយឱ្យទារកមានការធំធាត់ និង ការពារពីការប៉ះទង្គិចផ្សេងៗ។ ឧ. ការបែកទឹកភ្លោះជាសញ្ញាមួយនៃការត្រៀមប្រសូត។

អ. amniotic fluid
បារ. liquide amniotique

**ទុរាហារូបត្ថម្ភ**　　អាការៈកើតឡើងចំពោះមនុស្សឬសត្វនៅពេលទទួលទានអាហារមិនត្រឹមត្រូវតាមនិយាមនៃតម្រូវការ។ ឧ. មនុស្សឬសត្វត្រូវទទួលអាហារឱ្យបានគ្រប់គ្រាន់ដូចជាប្រូទីដ លីពីដ គ្លុយសុីដ ជីវជាតិ (vitamine) និងសារធាតុរ៉ែខនិជ...ដើម្បីជៀសវាងទុរាហា-រូបត្ថម្ភ។

អ. malnutrition
បារ. malnutrition (f.)

# ន

**នីដាស្យុង**
អ. nidation
បារ. nidation (f.)

ការតាំងទីរបស់អណ្ឌៈ (œuf fécondé) ទំនៅភ្នាសក្នុងនៃស្បូន ដែលជាទូទៅមានរយៈពេលពី៧ទៅ១០ថ្ងៃក្រោយពីកំណកំណើត។ ៕. ក្នុងករណីមិនប្រក្រតី នីដាស្យុង អាចកើតមាននៅដៃស្បូន ឬ ក្នុងធិទ្ធដ្ឋានពោះ (cavité abdominale) ដែលបង្កឱ្យទៅជាគភ៌ក្រៅស្បូន។

**នោមខ្ទុះ**
អ. pyuria
បារ. pyurie (f.)

វត្តមានខ្ទុះក្នុងទឹកមូត្រដែលបង្កឱ្យទឹកមូត្រនោះល្អក់ដែលជាអាការៈបញ្ជាក់អំពីអាំងហ្វិចស្យុង (infection) ប្រព័ន្ធទឹកមូត្រ។

**នោមច្រើន/ប៉ូលីយូរី**
អ. polyuria
បារ. polyurie (f.)

អាការៈកើនបរិមាណទឹកនោមដែលបញ្ចេញមកក្រៅលើសពី៣លីត្រក្នុងរយៈពេល ២៤ម៉ោង។

**នោមឈាម**
អ. hematuria
បារ. hématurie (f.)

វត្តមានគុលិកាឈាមក្រហមក្នុងទឹកនោមដែលជាការបញ្ជាក់អំពីជំងឺប្រព័ន្ធទឹកមូត្រ។

**នោមញឹក/ប៉ូឡាគ្យូរី**
អ. pollakiuria
បារ. pollakiurie (f.)

អាការៈនោមញឹកញាប់ ប៉ុន្តែនោមម្តងៗមានបរិមាណតិចដែលជារោគសញ្ញានៃជំងឺប្រូស្តាត (prostate)និងការរលាកប្លោកនោម(vessie)។

**នោមតិច/អូលីគូរី**
អ. oliguria
បារ. oligurie (m.)

អាការៈថយចុះបរិមាណទឹកនោម ដែលបញ្ចេញមកក្រៅក្រោម៥០០មិល្លីលីត្រក្នុងរយៈពេល២៤ម៉ោង ដែលជារោគសញ្ញានៃជំងឺតម្រងនោមជំងឺហើម និងការបាត់បង់លំនឹងអេឡិចត្រូលីត (électrolyte) ក្នុងចរន្តឈាម។

**នោមទាស់/ឌីស្សូរី**
អ. dysuria
បារ. dysurie (f.)

អាការៈឈឺចាប់ និងពិបាកនៅពេលនោម ដោយមូលហេតុរលាកបង្ហួរឬប្លោកនោម ដែលបណ្តាលមកពីកង្វះអនាម័យនៃប្រព័ន្ធទឹកមូត្រ និងប្រដាប់បន្តពូជខាងក្រៅ។

# ប

**បង់រុំ**
អ. band
បារ. bande (f.)

បន្ទះស្បៃ លោហធាតុ ឬប្លាស្ទិកទន់ប្រើក្នុងវេជ្ជសាស្ត្រសម្រាប់រុំព័ទ្ធសរីរាង្គណាមួយ។

**បន្ទប់វះកាត់/សល្យសាល**
អ. operating room/ operating theaters
បារ. bloc opératoire

បន្ទប់ស្តេរីលស្អាតមានអនាម័យត្រឹមត្រូវនៅក្នុងមន្ទីរពេទ្យ ដែលបំពាក់ដោយបរិក្ខារសម្រាប់ការវះកាត់តូចធំ និងការព្យាបាលផ្សេងៗទៀត។

**បន្ទុះស្បែក**
អ. skin eruption
បារ. éruption cutanée (f.)

កន្ទួលនៅលើស្បែកពណ៌ក្រហម ជួនកាលមានសណ្ឋានជាផ្លាក (taches) ជួនកាលមានសណ្ឋានជាពងទឹក (vésicules)។ អាការៈនេះ អាចមាន ឬគ្មានគ្រុនក្តៅ។ ឧ. ជំងឺកញ្រ្ជឹលបង្កឱ្យមានបន្ទុះស្បែកពណ៌ក្រហមស្ទើរពាសពេញសព៌ាង្គកាយ។

**បរាសិតវិទ្យា**
អ. parasitology
បារ. parasitologie (f.)

វិទ្យាសាស្ត្រសិក្សាពីពពួកបរាសិត (parasite)។

**ប៊ីស្ទូរី**
អ. bistoury
បារ. bistouri (m.)

ឧបករណ៍វេជ្ជសាស្ត្រដែលជាកាំបិតតូចៗ មានច្រើនប្រភេទសម្រាប់ប្រើក្នុងការវះកាត់។

**ប៊ូយ៉ុង**
អ. bouillon/broth
បារ. bouillon (m.)

ទឹករម្ងាស់ជាតិសាច់ បន្លែ...ប្រើក្នុងមីក្រុបវិទ្យា ដើម្បីធ្វើជាថ្នាលវប្បកម្ម។

**ប៊ូលីមី**
អ. bulimia
បារ. boulimie (f.)

ជំងឺសរសៃប្រសាទម្យ៉ាងដែលបង្កឱ្យអ្នកជំងឺ មានអាការៈឃ្លានខ្លាំងស៊ីមិនដឹងឆ្អែត។

**បាក់តេរ៉េមី/បាក់តេរីក្នុងឈាម**
អ. bacteremia
បារ. bactériémie (f.)

វត្តមានបាក់តេរីនៅក្នុងចរន្តឈាម។ ឧ. អាំងហ្វិចស្យុង (infection) ដែលបណ្ដាលឱ្យឡើងកម្ដៅ (គ្រុន) ជារោគសញ្ញានៃបាក់តេរ៉េមី។

**បាក់តេរី**
អ. bacterium
បារ. bactérie (f.)

អតិសុខុមប្រាណមានលក្ខណៈជាឯកកោសិកា រស់នៅក្នុងដី ទឹក និងខ្យល់ដែលមានផលប្រយោជន៍ ឬបង្កជំងឺដល់មនុស្ស សត្វ និងរុក្ខជាតិ។ បាក់តេរីមានសណ្ឋានច្រើនប្រភេទនិងមានសកម្មភាពខុសប្លែកៗពីគ្នា។ ឧ.១-បាក់តេរីស្ដាហ្វីឡូកូក (staphylocoque) ជាភ្នាក់ងារ បង្កឱ្យកើតបូស។ ឧ.២-បាក់តេរីនៅក្នុងយ៉ាអួ (yaourt) ជាបាក់តេរីមានប្រយោជន៍។

**បាក់តេរីយូរី**
អ. bacteriuria
បារ. bactériurie (f.)

វត្តមានបាក់តេរីដ៏ច្រើនលើសលប់នៅក្នុងទឹកនោមថ្មីៗ។ ឧ. សិបទីសេមី(septicémie) បង្កឱ្យមានបាក់តេរីយូរី។

**បាក់តេរីយោតេរ៉ាពី/ បាក់តេរីព្យាបាល**
អ. bacteriotherapy
បារ. bactériothérapie (f.)

ការប្រើបាក់តេរីរស់ឬរំងាប់សម្រាប់ព្យាបាលជំងឺដែលបង្កដោយបាក់តេរីចង្រៃ។ ឧ. ការប្រើសេរ៉ូមអង់ទីតេតានិក (sérum antitétanique) ជាវិធីមួយក្នុងចំណោមបាក់តេរីព្យាបាល។

**បាក់តេរីយោស្តាទិក**
អ. bacteriostatic/ bacteriostasis
បារ. bactériostatique (m.)

សារធាតុដែលអាចបញ្ឈប់ឬទប់ស្កាត់ការរីកលូតលាស់របស់បាក់តេរី។ ឧ. អង់ទីប្យូទិក និងអង់ទីសិបទិកមួយចំនួនជាបាក់តេរីយោស្តាទិក។

**បាក់តេរីវិទ្យា**
អ. bacteriology
បារ. bactériologie (f.)

វិទ្យាសាស្ត្រមូលដ្ឋានជាផ្នែកមួយនៃជីវមីក្រុបវិទ្យា (microbiologie) ដែលសិក្សាអំពីលក្ខណៈសណ្ឋាន ការលូតលាស់វដ្តជីវិត និង សកម្មភាពរបស់បាក់តេរីទៅលើសរីរាង្គកាយមនុស្ស សត្វ និងរុក្ខជាតិ។ ឧ. បាក់តេរីវិទ្យាជាមុខវិជ្ជាមូលដ្ឋានមួយដែលសិក្សាស្រាវជ្រាវទូលំទូលាយអំពីបាក់តេរីក្នុងវិស័យជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម។

**បាក់តេរីស៊ីដ/**
**បាក់តេរីឃាត**
អ. bactericide
បារ. bactéricide ( m. )

សារធាតុដែលសម្លាប់ជាស្ថាពរនូវពពួកបាក់តេរី។ ឧ. ដាហ្សេណាង់ ( dagénan ) ជាបាក់តេរីស៊ីដដែលគេប្រើនៅក្រោយសង្គ្រាមលោកលើកទី២។

**បារម្ភ**
អ. worry
បារ. inquiétude ( f. )

អាការៈខ្វល់ខ្វាយក្នុងចិត្តអំពីហេតុការណ៍ដែលអាច ឬ មិនអាចកើតមានឡើង។

**បាស៊ីយ៍/បាស៊ី**
អ. bacillus
បារ. bacille ( m. )

ពពួកបាក់តេរីឯកកោសិកាមានរាងដូចកូនដំបងដែលអាចរស់នៅក្នុងដី ទឹក ខ្យល់ សព៌ាង្គកាយ ...។

**បាស៊ីយ៍ឃ្លង់ /**
**បាស៊ីហង់សិន**
អ. hansen's bacillus
បារ. bacille de hansen ( m. )

បាក់តេរីម្យ៉ាងដែលបង្ករោគឃ្លង់។ បាក់តេរីនេះរកឃើញនៅគ.ស.១៨៧៣ ដោយជនជាតិន័រវែសឈ្មោះ ហង់សិន ( Gerhard Armauer Hansen )។

| | |
|---|---|
| **បាស៊ីយ៍/របេង/ បាស៊ីយ៍កុក**<br>អ. tuberculosis bacillus<br>បារ. bacille de la tuberculose/ bacille de koch | បាក់តេរីម្យ៉ាងដែលបង្ករោគរបេងចំពោះមនុស្ស និងសត្វ។ បាក់តេរីនេះរកឃើញនៅ គ.ស.១៨៨២ ដោយជនជាតិអាល្លឺម៉ង់ឈ្មោះ រ៉ូប៊ែរកុក (Robert Koch)។ |
| **បេសេហ្សេ(វ៉ាក់សាំង)**<br>អ. bacillus calmette guérin (vaccine)<br>បារ. BCG (vaccin)/ bacille bilié calmette-Guérin (vaccin) | វ៉ាក់សាំងការពាររោគរបេង ដែលរកឃើញនៅចន្លោះ គ.ស.១៩០៤-១៩២៨ ដោយជនជាតិបារាំងឈ្មោះ លោកអាល់ប៊ែរកាល់ម៉ែត (Albert Calmette) និងលោក កាមី(យ៍) ហ្គេរ៉ាំង (Camille Guérin)។ |
| **ប្រមេះទឹកបាយ**<br>អ. blennorrhagia/ gonorrhea<br>បារ. blennorragie/ gonorrhée (f.) | ជំងឺម្យ៉ាងដែលមានអាការៈហូរខ្ទុះយ៉ាងច្រើន តាមបង្ហូរនោម ដោយសារអាំងហ្វិចស្យុងនៃ បាក់តេរីហ្គោណូកូក (gonocoque)។ ឱ. ជំងឺប្រមេះទឹកបាយភាគច្រើនឆ្លងតាមការរួមភេទដោយពុំបានប្រុងប្រយ័ត្ន។ |

**ប្រសូតិកម្ម**

អ. child birth/ delivery/parturition

បារ. accouchement (m.)/parturition (f.)

ការសម្រាលទារកនិងឧបសម្ព័ន្ធចេញពីផ្ទៃម្ដាយ ដែលមហាជននិយមហៅថាការសម្រាលកូន ឬការឆ្លងទន្លេ។ ឱ. ដាទូទៅ ថ្ងៃទី២៨០នៃគភ៌ជាថ្ងៃកំណត់នៃប្រសូតិកម្ម។

**ប្រសូតិកម្មពិបាក**

អ. dystocic delivery

បារ. accouchement dystocique

ការសម្រាលទារករបស់ស្ត្រីមានគភ៌តាមផ្លូវធម្មជាតិដោយពិបាកឬមិនរួចបណ្ដាលមកពីត្រគាកម្ដាយចង្អៀតឬមកពីទារកមានក្បាលធំពេកដែលចាំបាច់ទាមទារឱ្យគ្រូពេទ្យដោះស្រាយតាមបច្ចេក-ទេសជំនាញ។

**ប្រសូតិកម្មមិនគ្រប់ខែ**

អ. premature birth/ premature delivery/ premature parturition

បារ. accouchement prématuré/accou-chement avant terme

ការសម្រាលទារកដែលនៅមានជីវិតនិងឧបសម្ព័ន្ធចេញពីផ្ទៃម្ដាយមុនកាលកំណត់។ ឱ. ប្រសូតិកម្មមិនគ្រប់ខែច្រើនកើតឡើងនៅចន្លោះសប្ដាហ៍ទី ៣៥ និង៣៦នៃគភ៌ដែលវិទ្យាសាស្ត្របច្ចុប្បន្នអាចសង្គ្រោះជីវិតទារកបាន១០០%។

**ប្រសូតិវិទ្យា/ សម្ភពវិទ្យា**
អ. obstetrics
បារ. obstétrique (f.)

វិទ្យាសាស្ត្រសិក្សាអំពីគភ៌និងការបង្កើតទារក។ ឧ. ធ្មបមានមុខងារសំខាន់ក្នុងការបម្រើផ្នែករោគស្ត្រីនិងប្រសូតិវិទ្យា។

**ប្រូទីដ**
អ. protid
បារ. protide (m.)

សារធាតុផ្សំឡើងដោយកាបោន(C) អ៊ីដ្រូហ្សែន(H) អុកស៊ីហ្សែន(O) និងអាសូត(N) ដែលឯកតាដំបូង គឺជាអាស៊ីដអាមីណេ(acide aminé) ជាច្រើនតភ្ជាប់គ្នាដោយសម្ព័ន្ធប៉ិបទីដ(peptide)។ ឧ. សារធាតុប្រូទីដមានច្រើននៅក្នុងគ្រាប់ធញ្ញជាតិ ជាពិសេសគ្រាប់សណ្ដែកសៀងក្នុងសាច់សត្វក្នុងបន្លែ...។

**បំណាក់ឆ្អឹងចំហ**
អ. open fracture
បារ. fracture ouverte (f.)

បំណាក់ឆ្អឹងដោយមានរយះសាច់និងធ្លាយស្បែកនៅចំកន្លែងបាក់នោះ ដែលបង្កឱ្យមានការហូរឈាមចេញមកក្រៅ។

**បំណាក់ឆ្អឹងបិទ**
អ. closed fracture
បារ. fracture fermée (f.)

បំណាក់ឆ្អឹងដោយគ្មានរបួសឬធ្លាយស្បែក ដែលអាចបង្កឱ្យមានកំណកឈាម(hématome) នៅត្រង់កន្លែងនោះ។

**បំណាក់ឆ្អឹងមានជំងឺ**
អ. pathologic fracture
បារ. fracture pathologique (f.)

បំណាក់ឆ្អឹងចំពោះឆ្អឹងដែលកំពុងមានជំងឺរ៉ាំរ៉ៃ ដូចជា របេងឆ្អឹង មហារីកឆ្អឹងឬទុយម័រផ្សេងៗ របស់ឆ្អឹង។ ឧ. បំណាក់ឆ្អឹងមានជំងឺរបេងឆ្អឹងខ្នង (mal de pott) អាចធ្វើឱ្យជើងអ្នកជំងឺទាំងសងខាងស្លាប់ស្ពឹក (paraplégie)។

**បំណាក់ឆ្អឹងឯកឯង**
អ. spontaneous fracture
បារ. fracture spontanée (f.)

បំណាក់ឆ្អឹងបណ្ដាលមកពីគ្រោះថ្នាក់តិចតួចមិននឹកស្មានដល់ ដែលគេជួបប្រទះភាគច្រើននៅលើស្ត្រីវ័យចំណាស់និងឆ្អឹងផុយស្រួយ(ostéopénie)។

**បំណាក់ជាពីរ/ អាប់រុបស្យុង**
អ. abruption
បារ. abruption (f.)

ការបាក់ទទឹងឆ្អឹងជាពីរកំណាត់ដែលមានលក្ខណៈគគ្រាតត្រង់មុខបាក់។ [ពាក្យនេះប្រើក្នុងត្រូម៉ាតូវិទ្យា (traumatologie)]។

# ផ

**ផឿក** អាការៈគ្មានជាតិពណ៌ម៉េឡានីន (pigment de la mélanine) នៃស្បែក (ភ្នែក សក់ រោម...) ពីកំណើតពេញទាំងខ្លួន ឬផ្នែកណាមួយនៃសព៌ាង្គកាយ។

អ. albinism

បារ. albinisme (m.) / albinie (f.)

**ផែនការគ្រួសារ** គម្រោងឱ្យមានកូនតាមគោលបំណង ដូចជាការពន្យារកំណើត ការអប់រំសុខភាព ការទប់កំណើត ជាដើមដើម្បីកាត់បន្ថយការប៉ះពាល់ដល់សុខភាពម្ដាយនិងកូន ព្រមទាំងសេដ្ឋកិច្ចគ្រួសារ។

អ. family planning

បារ. planning familial (m.)/planification familiale (f.)

**ពកសាច់ដុំ**
អ. myoma
បារ. myome (m.)

ដុំពកស្លូត (tumeur b́enigne) កើតឡើងពីជាលិកាសាច់ដុំមិនប្រក្រតី។

**ពងស្វាស**
អ. testes/testicle/testis
បារ. testicule (m.)

ក្រពេញភេទរបស់មនុស្សប្រុស ឬសត្វឈ្មោល។ នៅពេលពេញវ័យ ក្រពេញភេទនេះអាចផលិតស្ពែម៉ាតូសូអ៊ីត (spermatozoïde) និង អ័រម៉ូនតេស្តូតេរ៉ូន (hormone testotérone) / អង់ដ្រូហ្សែន។ ឧ. ការចងបំពង់ទឹកកាមដែលចេញពីពងស្វាសជាវិធីពន្យារកំណើតមួយបែប។

**ពេញវ័យ/ មជ្ឈិមវ័យ**
អ. adult
បារ. adulte (m.)/(f.)

វ័យរបស់មនុស្សចាប់ពីវ័យជំទង់រហូតដល់វ័យចាស់។

**ពេទ្យព្យាបាល**
អ. therapist
បារ. thérapeute(m.)

អ្នកវេជ្ជសាស្ត្រដែលមានចំណេះជំនាញក្នុងការព្យាបាលជំងឺ។

**ពោះ**
អ. abdomen
បារ. abdomen(f.)

ផ្នែកនៃដងខ្លួនស្ថិតនៅចន្លោះទ្រូងនិងឆ្អឹងត្រគាកដែលក្នុងនោះមានប្រព័ន្ធរំលាយអាហារ ប្រព័ន្ធទឹកមូត្រ និងសរីរាង្គដទៃទៀត។

**ព្យាបាលវិទ្យា/ វិទ្យាសាស្ត្រព្យាបាល**
អ. therapeutics
បារ. thérapeutique( f. )

វិទ្យាសាស្ត្រសិក្សាអំពីវិធីព្យាបាលនិងថែទាំដើម្បីឱ្យអ្នកជំងឺជាសះស្បើយ។

**ព្រូនចង្កឹះ**
អ. ascarid
បារ. ascaris/ascaride ( m. )

បរាសិតណេម៉ាតូដ( nématodes) ដែលមានរាងបំពង់វែង( cylindre )ពណ៌ប្រផេះ ឬពណ៌ក្រហម មានប្រវែងពី២០ទៅ៤០សង់ទីម៉ែត្រដែលរស់នៅក្នុងសព៌ាង្គកាយមនុស្សឬសត្វ។ ឧ. ក្មេងហូបចុកគ្មានអនាម័យនាំឱ្យកើតព្រូនចង្កឹះ។

**ព្រូនតម្លក់**
អ. hookworm
បារ. ankylostome ( m. )/necator americanus

បរាសិតណេម៉ាតូដ( nématodes )មានប្រវែងពី៨ទៅ១៥មីល្លីម៉ែត្រ។ បរាសិតនេះរស់នៅ និងជញ្ជក់ឈាមនៅត្រង់គល់ពោះវៀន( duodénum ) បណ្ដាលឱ្យមានជំងឺស្លេកស្លាំង។ ជាទូទៅវាឆ្លងតាមមាត់ឬស្បែក។

**ព្រូនសំប៉ែត/ព្រូនវែង (តេនញ៉ា )**
អ. tapeworm
បារ. taenia ( m. )

បរាសិតសេស្តូដ( cestodes )មានច្រើនប្រភេទ រស់នៅក្នុងពោះវៀនមនុស្ស និង សត្វមានឆ្អឹងកង ( vertébré )មានប្រវែងពី១៣មីល្លីម៉ែត្ររហូតដល់៩ម៉ែត្រមានសណ្ឋានជាកង់ៗ ហើយមានឈ្នប់នៅនឹងក្បាលសម្រាប់ថ្ពក់ជាប់ទៅនឹងស្រទាប់ខាងក្នុងនៃពោះវៀន។

**ព្រូនអន្ទង់**
អ. eelworm
បារ. anguillule ( f. )

បរាសិតណេម៉ាតូដ( nématodes )មានប្រវែង២មីល្លីម៉ែត្រ ឆ្លងតាមស្បែក បង្កឱ្យកើតជាកន្ទាលត្រអាករមាស់។ នៅពេលដែលបរាសិតនេះចូលទៅដល់សួត វាបង្កឱ្យមានជំងឺសួត ឱ្យមានជំងឺក្អកចុកទ្រូងជាដើម។ បន្ទាប់មកទៀត វាអាចបង្កឱ្យមានជំងឺផ្លូវរំលាយអាហារ ដូចជាការឈឺចុកចាប់ក្នុងពោះទល់លាមក រាករូស និងបង្កឱ្យមានជំងឺស្លេកស្លាំង។

**ព័ត៌មានជំងឺ**
អ. anamnesis
បារ. anamnèse ( f. )

ដំណឹងស្ដីពីស្ថានភាពជំងឺដែលអ្នកជំងឺ ឬសមាជិកគ្រួសាររៀបរាប់ភ្លាមៗប្រាប់គ្រូពេទ្យ។

# ភ

**ភាពជាំ**
អ. ecchymosis
បារ. ecchymose ( f. )

អាការៈមានគុលិកាឈាមជ្រាបចូលក្នុងជាលិកាគ្របដណ្ដប់ដែលបង្កឡើងដោយត្រូម៉ា ឬ ដោយការជ្រាបឈាមចេញពីសរសៃប្លូរ/សរសៃកាពីលែ ( capillaires )។

**ភាពជូរ/អាស៊ីដភាព**
អ. acidity
បារ. acidité ( f. )

កម្រិតជាតិអាស៊ីដ ឬជាតិជូរនៅក្នុងល្បាយមួយដែលមានpHក្រោម៧។

**ភាពមានគភ៌**
អ. pregnancy
បារ. grossesse( f. )

ភាពស្ត្រីមានផ្ទៃពោះចាប់ពីថ្ងៃបង្កកំណើត (ថ្ងៃបាត់រដូវ) រហូតដល់ថ្ងៃសម្រាល។ ប្រជាជនខ្មែរនិយមប្រើពាក្យ៖ ទ្រង់គភ៌ (រាជសព្ទ) ការមានគភ៌ ការមានផ្ទៃពោះ ការមានទម្ងន់ ការពពោះ ស្ត្រីផើម។
ឱ. ជាធម្មតាស្ត្រីមានគភ៌មានរយៈពេល២៨០ថ្ងៃ។

**ភាពមិនប្រក្រតី/អណូម៉ាលី**
អ. anomaly
បារ. anomalie ( f. )

លក្ខណៈខុសប្លែកពីធម្មតានៃសរីរាង្គណាមួយរបស់សព៌ាង្គកាយ។

**ភាពស៊ាំ** ដំណើរនៃសរីរាង្គ ដែលអាចទប់ស្កាត់មិនឱ្យឆ្លងជំងឺពីខាងក្រៅដែលបង្កឡើងដោយភ្នាក់ងារបង្កជំងឺណាមួយ។ ឧ. ការចាក់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេ(B)បង្កឱ្យមានភាពស៊ាំនឹងជំងឺនេះបាន។

អ. immunity

បារ. immunité (f.)

**ភាពឡើងខ្លាញ់** កំណើននៃសារធាតុខ្លាញ់ឡើងខ្ពស់នៅក្នុងជាលិកាដែលជាទូទៅបង្កឱ្យធាត់។

អ. adiposis

បារ. adipose/adiposité (f.)

**ភាពឥតអារ/ហ្វែទីលីតេ** លទ្ធភាព/សម្បទារបស់មនុស្ស សត្វ និងរុក្ខជាតិដែលអាចបន្តពូជបានចំពោះមនុស្ស គឺចាប់ពីពេលពេញក្រមុំរហូតដល់ពេលអស់រដូវ។

អ. fertility

បារ. fertilité (f.)

**ភាពអារ** ការមិនអាចបង្កកំណើតបាន(មនុស្ស សត្វ និងរុក្ខជាតិ)។ ឧ. ចំហាយវិទ្យុសកម្មបង្កឱ្យមានភាពអារឪពុកម្ដាយ ឬរូបភាពទារក។

អ. sterility

បារ. stérilité (f.)

**ភើ** ដំណើរចេញឧស្ម័នពីក្រពះមកតាមមាត់។ ឧ. អ្នកឈឺក្រពះច្រើនមានភើជាញឹកញាប់។

អ. eructation/belching

បារ. éructation (f.)

**ភើជូរ**
អ. acid regurgitation
បារ. régurgitation acide ( f. )

ដំណើរចេញឧស្ម័នពីក្រពះមកតាមមាត់ដោយមានជាតិជូរ។ ឧ. ការភើជូរជារោគសញ្ញាមួយនៃជំងឺក្រពះ។

**ភ្នាសក្នុងស្បូន/អង់ដូម៉ែត្រ**
អ. endometrium
បារ. endomètre ( m. )

ស្រទាប់ជាលិកាដែលពាសផ្ទៃខាងក្នុងបំផុតនៃស្បូន និងដៃស្បូន ( trompe de fallope )។ ឧ. អង់ដូម៉ែត្រជាទីតាំងនីដាស្យុង ( nidation ) នៃគភ៌ដែលទំនៅក្នុងស្បូន។

**ភ្នាសទារកក្នុងផ្ទៃ**
អ. fetal membrane
បារ. membrane fœtale ( f. )

អន្តរសរីរាង្គមួយផ្នែកនៃគភ៌ក្នុងស្បូនមានសណ្ឋានជាស្រោមស្តើងស្រោបទារក ដែលមានពីរស្រទាប់ គឺអាម៉្ញូស ( amnios ) និងកូរីយ៉ុង ( chorion )។ ឧ. ក្នុងករណីមានទឹកភ្លោះច្រើន/អ៊ីដ្រាម៉្ញូស ( hydramnios ) គ្រូពេទ្យត្រូវបោះភ្នាសទារកក្នុងផ្ទៃដើម្បីពន្លឿនប្រសូតិកម្មតាមផ្លូវធម្មជាតិ។

# ម

**មនុស្សផ្សៀក** មនុស្សដែលគ្មានជាតិពណ៌ម៉េឡានីន (pigment de la mélanine) នៅស្បែក (ភ្នែក សក់ រោម...) ពីកំណើត។
អ. albino
បារ. albinos (m.)

**មរណាសន្នកាល/អាហ្គោនី** ដំណាក់កាលស្លូឈាមមុនស្លាប់របស់អ្នកជំងឺដោយសារកង្វះអុកស៊ីហ្សែនទៅចិញ្ចឹមខួរក្បាល។
អ. agony
បារ. agonie (f.)

**មហារីកវិទ្យា** វិទ្យាសាស្ត្រសិក្សាពីជំងឺមហារីក វិធីសាស្ត្រការពារ និង ព្យាបាល។
អ. cancerology
បារ. cancérologie (f.)

**មាត់ឆែប/ឆែបមាត់** វិរូបភាពពីកំណើតដែលបបូរមាត់ និង/ឬ ក្រអូមមាត់ខាងលើមានសណ្ឋានជារង្វះប្រហ។
អ. cleft lip/cleft palate
បារ. bec-de-lièvre (m.)

**មីកូវិទ្យា** វិទ្យាសាស្ត្រសិក្សាពីជំងឺដែលបង្កដោយមេរោគជាពពួកផ្សិត (champignon)។
អ. mycology
បារ. mycologie (f.)

**មីញ៉ូតូនី**
អ. myotonia
បារ. myotonie (f.)

ការកន្ត្រាក់សាច់ដុំ ឬ ប្រព័ន្ធសាច់ដុំដោយកម្លាំងសាច់ដុំផ្ទាល់ ឬ ដោយរំញោចពីខាងក្រៅបណ្ដាលឱ្យសាច់ដុំនោះឡើងរឹងមួយរយៈពេលខ្លី។

**មីញ៉ូសាកូម**
អ. myosarcoma
បារ. myosarcome (m.)

មហារីកសាច់ដុំទាំងពីរប្រភេទគឺសាច់ដុំឆ្នូត (muscle strié) និង សាច់ដុំរលីង (muscle lisse) ដែលមានលក្ខណៈកាចសាហាវដោយសារការរីករាលដាលកោសិកាមហារីកលឿនតាមរយៈចរន្តឈាម និង ចរន្តឡាំហ្វ៍។

**មុខរបួស**
អ. wound
បារ. plaie (f.)

អាការៈដាច់រហែក ឬ បាត់បង់ជាលិកាគ្របដណ្ដប់សព៌ាង្គកាយ ឬ សរីរាង្គដែលបង្កឡើងដោយការប៉ះទង្គិច។

**មុន**
អ. acne
បារ. acné (f.)

ជំងឺស្បែកមានលក្ខណៈរលាក និងមានខ្ទុះនៅក្នុងក្រពេញញើស (glande sébacée) ឬ ក្រពេញគល់រោម (glande pilosébacée) ជាពិសេសនៅស្បែកមុខ និងខ្នង ប៉ុន្តែបាតដៃឬបាតជើងពុំមានកើតមុនទេ។

**មូត្រព្យាបាល**
អ. urotherapy
បារ. urothérapie (f.)

វិធីវេជ្ជសាស្ត្រវិភាគនិងព្យាបាលជំងឺប្រព័ន្ធទឹកនោម។

**មូត្រវិទ្យា** វិទ្យាសាស្ត្រសិក្សាអំពីប្រព័ន្ធទឹកនោម ជំងឺ និងវិធីព្យាបាល។
អ. urology
បារ. urologie (f.)

**មេតាស្តាស** ការរីករាលដាលកោសិកាមហារីក បាក់តេរី វីរុស ឬបរាសិតតាមចរន្តឈាមឬចរន្តឡាំហ្វ៍ ចេញពីចំណុចដើមទៅសរីរាង្គដទៃទៀត។
អ. metastasis
បារ. métastase (f.)

# ៥៩

**យានសង្គ្រោះ** មធ្យោបាយដឹកជញ្ជូនដែលមានបំពាក់ឧបករណ៍
អ. ambulance វេជ្ជសាស្ត្រដើម្បីជួយសង្គ្រោះបន្ទាន់ដល់អ្នកជំងឺ
បារ. ambulance (f.) អ្នករបួស ជនរងគ្រោះផ្សេងៗ ឬ ដឹកសាកសព។

# រ

**រដូវច្រើន/មេណូរ៉ាហ្សី**
អ. menorrhagia/ hypermenorrhea
បារ. ménorragie/ hyperménorrhée (f.)

អាការៈធ្លាក់ឈាមរដូវស្ត្រីក្នុងបរិមាណច្រើន និងជួនកាលមានរយៈពេលវែងខុសធម្មតា ដែលអាចបណ្ដាលមកពីវិបត្តិកំណកឈាម វិបត្តិលំនឹងអ័រម៉ូន ឬ ទុយម័របេនីញរបស់ស្បូន។ ស្ត្រីធ្លាក់រដូវច្រើនបង្កឱ្យមានអាការៈស្លេកស្លាំងអស់កម្លាំងជាប្រចាំដែលតម្រូវឱ្យអ្នកជំងឺនោះទៅពិគ្រោះជាមួយគ្រូពេទ្យឯកទេស។

**រដូវដំបូង/មេណាក**
អ. menarche
បារ. ménarche (m.)/ ménarchie (f.)

ដំណើរធ្លាក់រដូវដំបូងរបស់ស្ត្រីក្រមុំ។ ឧ. ស្ត្រីក្រមុំអាចមានរដូវដំបូងចាប់ពីអាយុ៩ទៅ១៦ឆ្នាំ។

**រដូវតិច/អូលីហ្គោមេណូរេ**
អ. oligomenorrhea
បារ. oligoménorrhée (f.)

អាការៈធ្លាក់ឈាមរដូវស្ត្រីក្នុងបរិមាណតិចតួចខុសធម្មតា។ មូលហេតុដែលបង្កឱ្យមានរដូវតិចគឺវិបត្តិលំនឹងអ័រម៉ូន វិបត្តិផ្លូវចិត្ត កង្វះអាហារូបត្ថម្ភ និងជំងឺមួយចំនួនទៀត។

**រដូវលំបាក**
អ. dysmenorrhea
បារ. dysménorrhée (f.)

ការឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ ក្នុងរយៈពេលដែលស្ត្រីមានរដូវ។ ឧ. នៅពេលមានរដូវលំបាកស្ត្រីអាចប្រើឱសថបន្ថយការឈឺចាប់បាន។

**រដូវស្ត្រី**
អ. menses
បារ. règles/menstruation (f.)

ការធ្លាក់ឈាមពីស្បូនប្រចាំខែរបស់ស្ត្រីក្នុងវ័យបន្តពូជ ក្រៅពីពេលមានគភ៌ ដែលជាធម្មតាមានរយៈពេលពី៣ទៅ៧ថ្ងៃ។ ឧ. ក្មេងស្រីដែលមានរដូវស្ត្រីជាលើកដំបូងបញ្ជាក់ថាក្មេងស្រីនោះពេញក្រមុំ។

**របួមតូច/អត្រេស៊ី**
អ. atresia
បារ. atrésie (f.)

អាការៈរួមតូចនៃបំពង់ ឬ រន្ធរបស់សរីរាង្គដែលមានលក្ខណៈជាវិរូបភាពពីកំណើត ឬ ក្រោយកំណើត ហើយដែលធ្វើឱ្យមុខងារសរីរាង្គនោះថយចុះ ឬ បាត់បង់។

**របួស**
អ. injury
បារ. blessure (f.)

ភាពដាច់រហែកជាលិកានៃសរីរាង្គដែលបង្កដោយគ្រោះថ្នាក់ផ្សេងៗ។

**រលាកភ្នាសក្នុងនៃស្បូន/អង់ដូមេទ្រីត**
អ. endometritis
បារ. endométrite (f.)

អាំងហ្វិចស្យុងស្រទាប់ក្នុងនៃស្បូន (endomètre) ដៃស្បូន (trompe de fallope) ដែលមានលក្ខណៈស្រួចស្រាល់ឬរ៉ាំរ៉ៃជាពិសេសអាចកើតមានក្រោយពេលសម្រាល ក្រោយពេលរលូតកូន ឬ ក្រោយពេលដាក់កងក្នុងស្បូន។ ឧ. អង់ដូមេទ្រីតទាមទារឱ្យមានការព្យាបាលត្រឹមត្រូវ ដើម្បីជៀសវាងនូវផលវិបាក

ច្រើនយ៉ាងដូចជា ការស្ទះបំពង់ដៃស្បូន ការបង្ក ឱ្យមានភាពអារ ឬ ការមានគភ៌ក្រៅស្បូន។

**រលាកមាត់ស្បូន/ សែរវីស៊ីត**
អ. cervicitis
បារ. cervicite (f.)

អាការៈអាំងហ្វិចស្យុងនៃមាត់ស្បូន ដែលបណ្ដាល មកពីផ្សិត បាក់តេរី...មានលក្ខណៈរលាក ក្រហម ធ្លាក់ស ជួនកាលបង្កឱ្យរមាស់ និងឈឺផ្សាផ្នែក ខាងក្រៅនៃប្រដាប់បន្តពូជ និងអាចបង្កឱ្យធ្លាក់ ឈាមតិចៗនៅពេលរួមសង្វាស។

**រលាកស្បូន/មេទ្រីត**
អ. metritis
បារ. métrite (f.)

អាការៈរលាកជាទូទៅនៃជាលិកាស្បូនចាប់ពីភ្នាស ក្នុងនៃស្បូន (muqueuse utérine) រហូតដល់ សាច់ដុំនៃស្បូន (muscle utérin)។ ឧ. មេទ្រីតជា អាំងហ្វិចស្យុងធ្ងន់ធ្ងរ តម្រូវជាចាំបាច់ឱ្យអ្នកជំងឺ ទៅជួបនឹងគ្រូពេទ្យឯកទេសរោគស្ត្រី ដើម្បីពិនិត្យ និងព្យាបាល។

**រេសិចស្យុង**
អ. resection
បារ. résection (f.)

ការកាត់ឬច្រឹបតាមវិធីវេជ្ជសាស្ត្រនូវផ្នែកសរីរាង្គ ខាងក្នុងណាមួយ ឬសរីរាង្គទាំងមូល បន្ទាប់មក ត្រូវដេរភ្ជិតឬដេរតភ្ជាប់ឱ្យមានដំណើរការឡើងវិញ។

**រោគក្អកមាន់**
អ. pertussis/ whooping cough
បារ. coqueluche (f.)

ជំងឺរាតត្បាតម៉្យាងបង្កឡើងដោយមេរោគឈ្មោះ បាស៊ី Bardetella pertussis/hæmophilus pertussis ឬ bacillus pertussis។ ជាទូទៅ រោគនេះកើតនៅលើទារក ឬ កុមារដោយការក្អក កន្ត្រាក់យ៉ាងខ្លាំងជាប់ៗគ្នានិងមានរយៈពេលយូរ។

នៅពេលដកដង្ហើមចូលក្រោយការក្អកម្តងៗមាន
ឮសូរដូចសំឡេងមាន់ ជួនកាលទារក ឬ កុមារហូរ
ទឹកភ្នែក ទឹកសំបោរ និង ទឹកមាត់ទៀតផង។
ឧ. រោគក្អកមាន់អាចការពារបានដោយការចាក់ថ្នាំ
បង្ការ (vaccin)។

**រោគគ្រុនឈាម**
អ. dengue/
hemorrhagic fever/
dengue fever
បារ. dengue
hémorragique/
dengue (f.)

រោគឆ្លងតាមមូសខ្លាឈ្មោះ Aédes oegypti មកមនុស្សហើយច្រើនកើតនៅតំបន់ត្រូពិក។ រោគនេះ កើតឡើងដោយសារវីរុសឈ្មោះ dengue ដែលស្ថិតនៅក្នុងក្រុម flaviviridae។ ឧ. នៅរដូវភ្លៀងយើងត្រូវកម្ចាត់មូសខ្លា ដើម្បីកុំឱ្យកើតជំងឺគ្រុនឈាម។

**រោគគ្រុនពោះវៀន**
អ. typhoid fever
បារ. fièvre typhoïde

រោគឆ្លងដោយមេរោគឈ្មោះ សាលម៉ូណេឡាទីហ្វី (Salmonella typhi) ឬ មេរោគឈ្មោះបាស៊ីអេប៊ែរ (bacille d'Eberth)។ ឧ. អ្នកស្រាវជ្រាវបានចុះទៅពិនិត្យតំបន់ជនបទមួយកន្លែង ដែលមានកើតរោគគ្រុនពោះវៀនដោយមូលហេតុប្រើទឹកមិនស្អាត។

**រោគរបេង**

អ. tuberculosis

បារ. tuberculose (f.)

រោគឆ្លងតាមផ្លូវដង្ហើមបង្កឡើងដោយមេរោគឈ្មោះ បាស៊ីកុក( bacille de Koch BK : Myco bacterium tuberculosis) ដែលកើតឡើងនៅលើសរីរាង្គណាមួយរបស់មនុស្ស ឬ សត្វ ដូចជាសួត ឆ្អឹង ពោះវៀន តម្រងនោម ស្រោមខួរ កូនកណ្ដុរ។ល។ ឧ.១ អ្នកជំងឺដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យនេះ មានរោគរបេងសួត។ ឧ.២ កុមារនេះមានរោគរបេងកូនកណ្ដុរ (ប្រជាជនខ្មែរនិយមហៅថា កើតម្រេញ)។

**រោគស្វាយ**

អ. syphilis

បារ. syphilis (f.)

កាមរោគម៉្យាង ដែលបង្កឡើងដោយមេរោគឈ្មោះ Spirochète treponema pallidum de schaudinn។ ជំងឺនេះឆ្លងតាមការរួមភេទ និងពីម្ដាយទៅទារកក្នុងផ្ទៃ ដែលមានរោគសញ្ញាច្រើនបែប។ ជំងឺនេះអាចវិវត្តពីស្រាលទៅធ្ងន់តាមបីដំណាក់កាល។ បើគ្មានការព្យាបាលត្រឹមត្រូវ និងទាន់ពេលវេលានោះទេ វាអាចបណ្ដាលឱ្យខូចសរីរាង្គផ្សេងៗជាច្រើន និងអាចឱ្យស្លាប់បាន។ ឧ. ការប្រើប្រាស់ស្រោមអនាម័យធ្វើឱ្យអត្រានៃការឆ្លងរោគស្វាយមានការថយចុះ។

**រំហូរពីស្បូន** ការហូរសារធាតុរាវដែលអាចជាទឹករំអិល

អ. metrorrhea (mucus/glaire) ទឹកភ្លោះ (liquide amniotique)

បារ. métrorrhée (f.) ឬកម្ទេចកម្ទីផ្សេងៗពីក្នុងស្បូន។

# ល

**លីពីដ** សារធាតុប្រេង ខ្លាញ់ ដែលមិនរលាយក្នុងទឹក តែរលាយក្នុងធាតុរំលាយសរីរាង្គ (solvant organique) ហើយដែលមានម៉ូលេគុលអាស៊ីដ ប្រេង ខ្លាញ់ (acide gras)។

អ. lipid

បារ. lipide (m.)

**ល្បឺ** ការស្ដាប់ឮនៃសោតវិញ្ញាណ។

អ. audition

បារ. audition (f.)

**លំហូរឈាម** អាការៈមានឈាមហូរចេញពីសរសៃឈាមដាច់ ឬ របួស។

អ. hemorrhage/ bleeding

បារ. hémorragie (f.)

**លំហូរឈាមពីស្បូន/ មេត្រូរ៉ាហ្ស៊ី** អាការៈធ្លាក់ឈាមពីក្នុងស្បូន ក្រៅពីពេលមានរដូវ។ ឧ. ជំងឺស្បូនភាគច្រើនបង្កឱ្យមានមេត្រូរ៉ាហ្ស៊ី។

អ. metrorragia

បារ. métrorragie (f.)

# វ

**វក្កំ/តម្រងនោម**
អ. kidney
បារ. rein ( m. )

សរីរាង្គរបស់មនុស្សឬសត្វមានសណ្ឋានស្រដៀងនឹងគ្រាប់សណ្តែក ដែលមានមុខងារច្រោះយកជាតិអាសូតចេញពីឈាមបង្កើតជាទឹកនោមធ្វើឱ្យមានលំនឹងសារធាតុផ្សេងៗក្នុងឈាម។ ឧ. ជំងឺរលាកវក្កំ ឬ ជំងឺរលាកតម្រងនោម។

**វក្កំវិទ្យា**
អ. nephrology
បារ. néphrologie ( f. )

វិទ្យាសាស្ត្រសិក្សាអំពីជំងឺនិងវិធីព្យាបាលវក្កំ។

**វដ្តរដូវ**
អ. menstruel cycle
បារ. cycle menstrual ( m. )

ខួបរដូវរបស់ស្ត្រីចាប់ផ្តើមពីស្ត្រីពេញក្រមុំ ( puberté ) រហូតដល់វ័យអស់រដូវ ( ménopause )។ មួយខួបរដូវមានរយៈពេល២៨ថ្ងៃ រាប់ចាប់ពីថ្ងៃទី១នៃរដូវរហូតដល់ថ្ងៃទី២៨នៃខួបនីមួយៗ។ ឧ. អវត្តមានរបស់វដ្តរដូវជារោគសញ្ញាមួយបញ្ជាក់ថា ស្ត្រីនោះមានបញ្ហាសុខភាព។

**វយោហារូបត្ថម្ភ**
អ. denutrition
បារ. dénutrition ( f. )

ភាពទទួលជាតិអាហារជ្រួតជ្រាបតិចជាងជាតិអាហារដែលបញ្ចេញចោល។

**វ៉ាក់សាំង**
អ. vaccine
បារ. vaccin (m.)

សារធាតុដែលចាក់បញ្ចូលទៅក្នុងសរីរាង្គកាយមនុស្ស ឬសត្វបង្កបង្កើតបានជាអង់ទីករ (anticorps) អាចទប់ទល់បង្ការឬបង្កើតភាពស៊ាំនឹងជំងឺណាមួយ។
ឧ. ក្រសួងសុខាភិបាលមានកម្មវិធីជាតិចាក់វ៉ាក់សាំងដល់ទារកដែលទើបនឹងកើត។

**វិទ្យុព្យាបាល**
អ. radiotherapy
បារ. radiothérapie (f.)

វិធីសាស្ត្រព្យាបាលជំងឺដោយប្រើកាំរស្មីវិទ្យុសកម្ម។
ឧ. ការព្យាបាលដោយប្រើកាំរស្មីកូបាល់ (cobalt) ជាផ្នែកមួយនៃវិទ្យុព្យាបាលជំងឺមហារីក។

**វិរូបភាព**
អ. malformation
បារ. malformation (f.)

លក្ខណៈខុសប្រក្រតីពីកំណើតនៃសរីរាង្គណាមួយរបស់សព៌ាង្គកាយ។

**វិលមុខ**
អ. dizziness/vertigo
បារ. vertige (m.)

អាការៈងងឹតមុខស្លុប ងេងងោង ធេងធោង ដែលអ្នកជំងឺមានអារម្មណ៍ថា ខ្លួនឯងកំពុងតែវិល ឬមើលឃើញវត្ថុជុំវិញខ្លួនកំពុងវិល ឬយោលចុះយោលឡើង។

**វ័យកុមារ/បឋមវ័យ**
អ. childhood
បារ. enfance (f.)

វ័យរបស់មនុស្សចាប់ពីថ្ងៃកើតរហូតដល់វ័យជំទង់។

**វ័យចាស់/បច្ឆិមវ័យ** វ័យរបស់មនុស្សចាប់ពីពេញវ័យឡើងទៅ។

អ. old age

បារ. vieillesse ( f. )

**វ័យជំទង់** វ័យរបស់មនុស្សចាប់ពីវ័យកុមារហួតដល់ពេញវ័យ។

អ. adolescence

បារ. adolescence ( f. )

# ស

**សន្លាក់**
អ. joint/articulation
បារ. articulation (f.)

កន្លែងភ្ជាប់ឬតំណរវាងឆ្អឹងនិងឆ្អឹងដែលអាច ឬមិនអាចធ្វើចលនាបាន។ ឧ១. សន្លាក់ជង្គង់ជាសន្លាក់តពីឆ្អឹងភ្លៅទៅឆ្អឹងស្មងដែលអាចធ្វើចលនាបាន។ ឧ.២ សន្លាក់ថ្ងាសឆ្អឹងត្រគាកជាសន្លាក់មិនអាចធ្វើចលនាបាន។

**សន្លាក់វិទ្យា**
អ. arthrology
បារ. arthrologie (f.)

វិទ្យាសាស្ត្រសិក្សាជាមូលដ្ឋានអំពីសន្លាក់ ដែលជាផ្នែកមួយនៃកាយវិភាគវិទ្យា/អាណាតូមី (anatomie)។

**សម្រូប**
អ. absorption
បារ. absorption (f.)

ក្នុងសរីរវិទ្យា សម្រូបគឺជាការចូលសារធាតុពីខាងក្រៅទៅក្នុងសរីរាង្គណាមួយដោយពុំបង្កឱ្យមានត្រូម៉ា។ ឧ. សម្រូបអុកស៊ីហ្សែនចូលក្នុងថង់សួត (alvéole)។

**សម្អិតខះ**
អ. agglutination
បារ. agglutination (f.)

ការស្អិតខះជាប់គ្នារបស់កោសិកា ឬមីក្រូសពាង្គកាយដោយសារអន្តរកម្មរវាងអង់ទីហ្សែន និង អង់ទីករនៅពេលជួបគ្នា។

**សរីរព្យាបាល/**
**ហ្វីស្យូព្យាបាល**
អ. physiotherapy/
physical therapy
បារ. physiothérapie/
physicothérapie ( f. )

វិធីសាស្ត្រព្យាបាលជំងឺដោយប្រើភ្នាក់ងាររូប (agents physiques) ធម្មជាតិឬសិប្បនិម្មិត។
ឧ. ការស្អំក្បាលនឹងទឹកកកជាសរីរព្យាបាលមួយបែបក្នុងការព្យាបាលអាការៈឈឺក្បាល។

**សរីរវិទ្យា**
អ. physiology
បារ. physiologie ( f. )

វិទ្យាសាស្ត្រសិក្សាអំពីមុខងារសកម្មភាពនៃជាលិកា និង សរីរាង្គរបស់ភាវៈមានជីវិត។

**សល្យកម្មសព/**
**អូតុបស៊ី**
អ. autopsy
បារ. autopsie ( f. )

វិធីវះកាត់សាកសពដោយអ្នកជំនាញវេជ្ជសាស្ត្រធ្វើកោសល្យវិច័យដើម្បីរកមូលហេតុនៃមរណភាព ឬ ដើម្បីស្រាវជ្រាវវិទ្យាសាស្ត្រវេជ្ជសាស្ត្រ។

**សល្យព្យាបាល**
អ. surgical operation
បារ. opération
chirurgicale ( f. )

វិធីសាស្ត្រព្យាបាលជំងឺដោយការវះកាត់ ការចាក់នឹងម្ជុលឬការទាញតម្រង់ដោយដៃ។

**សល្យវិទ្យា**
អ. surgery
បារ. chirurgie ( f. )

វិទ្យាសាស្ត្រសិក្សាអំពីវិធីព្យាបាលជំងឺដោយវះកាត់ ចាក់នឹងម្ជុល ឬ ទាញតម្រង់។

**សារធាតុរំលូត** សារធាតុដែលបង្កឱ្យមានការរលូតកូន។ ឧ. ការប្រើសារធាតុរំលូតមិនតាមវេជ្ជបញ្ជាអាចបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិតម្ដាយ។

អ. abortifacient

បារ. abortif (m.)

**សិបទីសេមី** អាំងហ្វិចស្យុង (infection) ធ្ងន់ធ្ងរដោយសារបាក់តេរ៉េមី (bactérémie) ខ្ពស់បណ្ដាលឱ្យមានរោគសញ្ញាគ្រុនក្ដៅញាក់ និងអស់កម្លាំងខ្លាំងរហូតដល់ស្ហុក (choc)។ ឧ. អ្នកជំងឺសិបទីសេមីដែលពុំបានព្យាបាលទាន់ពេលវេលាអាចបណ្ដាលឱ្យស្លាប់ដោយសារស្ហុកសិបទីសេមីក (choc septicémique)។

អ. septicemia

បារ. septicémie (f.)

**សុក** អន្តរសរីរាង្គមានទីតាំងនៅក្នុងស្បូនភាគខាងលើដែលភ្ជាប់ពីម្ដាយទៅទារកក្នុងផ្ទៃតាមរយៈទងផ្ចិត។ សុកមានមុខងារបញ្ជូនអុកស៊ីហ្សែន សារជាតិអាហារ និងសារធាតុដទៃទៀតទៅចិញ្ចឹមទារក ហើយបញ្ចេញពីទារកមកម្ដាយវិញនូវឧស្ម័នកាបូនិក និងកាកសំណល់ផ្សេងៗ។ ឧ. ជាទូទៅសុកដែលធ្លាក់ចេញពីស្បូនម្ដាយក្រោយពេលសម្រាលមានទម្ងន់១/៦នៃទម្ងន់ទារក។

អ. placenta

បារ. placenta (m.)

**សុកពាំងមាត់ស្បូន/ផ្លាសង់តាប្រេ៉វីយ៉ា**
អ. placenta prœvia
បារ. placenta prœvia (m.)

សុកតាំងទីខុសប្រក្រតីនៅផ្នែកខាងក្រោមនៃស្បូន។ ឧ. សុកពាំងមាត់ស្បូន ជាករណីមានគ្រោះថ្នាក់ដល់ជីវិតដោយសារការធ្លាក់ឈាមយ៉ាងខ្លាំងនៅក្នុងត្រីមាសទីបីនៃគភ៌។

**ស្តេរីលកម្ម**
អ. sterilization
បារ. stérilisation (f.)

វិធីសម្លាប់មីក្រូសរីរាង្គដោយកម្តៅកាំរស្មីឬសារធាតុគីមី...។ ឧ. សម្ភារៈវះកាត់ត្រូវធ្វើស្តេរីលកម្មឱ្យបានស្អាតទើបជៀសវាងអាំងហ្វិចស្យុង (infection)។

**ស្ត្រូក**
អ. stroke/cerebro-vascular accident
បារ. accident vas-culaire cérébral (AVC) (m.)

ផលវិបាកស្រួចស្រាល់នៃខួរក្បាលបណ្តាលមកពីគ្រោះថ្នាក់ដោយតៀត ឬ ដាច់សរសៃឈាមក្នុងខួរក្បាល ឬ ក្នុងស្រោមខួរក្បាល ដែលបង្កជាកង្វះឈាមទៅចិញ្ចឹមខួរក្បាល។

**ស្ប៉ាស់**
អ. spasm
បារ. spasme (m.)

អាការៈឈឺចុកចាប់ភ្លាមៗដោយសារការកន្ត្រាក់សាច់ដុំដោយឯកឯង។ ឧ. ស្ប៉ាស់បំពង់ខ្យល់អាចបង្កឱ្យស្ទះដង្ហើម។

**ស្បូន**
អ. uterus
បារ. utérus (m.)

សរីរាង្គបន្តពូជរបស់ស្ត្រីដែលគភ៌មកតាំងទីនិងលូតលាស់។ ឧ. ការសម្រាលកូននៅក្នុង គ្រឹះស្ថានសុខាភិបាលអាចកាត់បន្ថយអត្រានៃការស្រុតស្បូន។

**ស្រួចស្រាល់**
អ. acute
បារ. aigu,-uë (adj.)

ដែលមានអាការៈឈឺទាន់ហន់ ហើយធ្ងន់ធ្ងរ ផ្ទុយនឹងអាការៈរ៉ាំរ៉ៃ (chronique)។

**ស្រួចស្រាល់កម្ម/ស្រួចស្រាល់នីយកម្ម**
អ. acutization
បារ. acutisation (f.)

ការវិវត្តជំងឺពីរ៉ាំរ៉ៃទៅស្រួចស្រាល់។

**សំដាប់ស្ទង់**
អ. auscultation
បារ. auscultation (f.)

ការស្តាប់សំឡេងសរីរាង្គក្នុងសព៌ាង្គកាយ ដូចជាសួត បេះដូង ពោះវៀនជាដើម ដើម្បីធ្វើរោគវិនិច្ឆ័យ ដោយប្រើត្រចៀកផ្ទាល់ ឬ ដោយប្រើឧបករណ៍វេជ្ជសាស្ត្រ។

# ហ

**ហ្វីប្រូម**
អ. fibroma
បារ. fibrome (m.)

ដុំពកបេនីញនៃជាលិកាសន្ធាន (tissu conjonctif) ដែលអាចកើតមាននៅគ្រប់សរីរាង្គនៃសព៌ាង្គកាយ។

**ហ្វីប្រូមស្បូន**
អ. uterus fibroma
បារ. fibroma utérin (m.)

ដុំពកបេនីញនៃជាលិកាសន្ធានរបស់ស្បូន។ ឧ. ហ្វីប្រូមស្បូនជាជំងឺដែលតម្រូវឱ្យវះកាត់យកចេញជាចាំបាច់ដើម្បីជៀសវាងការវិវត្តទៅជាមហារីកស្បូន។

**ហ្សីណេកូវិទ្យា/ រោគស្ត្រីវិទ្យា**
អ. gynecology
បារ. gynécologie (f.)

វេជ្ជវិទ្យាដែលសិក្សាអំពីសរីរាង្គបន្តពូជរបស់ស្ត្រី និង វិធីសាស្ត្រព្យាបាល។ ឧ. រោគស្ត្រីវិទ្យាបច្ចុប្បន្នកំពុងផ្ដោតការយកចិត្តទុកដាក់កាត់បន្ថយជំងឺមហារីកមាត់ស្បូន។

**អកាឌីយ៉ាក់** វិរូបភាពគ្មានបេះដូងពីកំណើត។
អ. acardiac
បារ. acardiaque (m.)

**អកាល់គុយលី** អសមត្ថភាពរបស់បុគ្គលក្នុងការគិតលេខ ដូចជា បូក ដក គុណ ចែក ជាដើម។
អ. acalculia
បារ. acalculie (f.)

**អកីរ៉ូប៉ូឌី** វិរូបភាពគ្មានប្រអប់ដៃនិងប្រអប់ជើងម្ខាង ឬទាំងសងខាងពីកំណើត។
អ. acheiropodia
បារ. acheiropodie (f.)

**អកីរី** វិរូបភាពគ្មានប្រអប់ដៃម្ខាងឬទាំងសងខាង ពីកំណើត។
អ. acheiria
បារ. acheirie (f.)

**អកូរី** វិរូបភាពគ្មានរន្ធប្រស្រីភ្នែកពីកំណើត។
អ. acoria
បារ. acorée/acorie (f.)

**អកូលី** អាការៈមិនប្រក្រតីរបស់ថ្លើមដែលគ្មានការបញ្ចេញ ទឹកប្រមាត់។
អ. acholia
បារ. acholie (f.)

**អកូលូរី** អាការៈមិនប្រក្រតីដោយគ្មានទឹកប្រមាត់ក្នុងទឹកមូត្រ។

អ. acholuria

បារ. acholurie ( f. )

**អកេលី** វិរូបភាពគ្មានបបូរមាត់មួយផ្នែកឬទាំងមូលពីកំណើត។

អ. acheilia

បារ. acheillie/

achélie/achilie ( f. )

**អក្រូម៉ាតុបស៊ី** អាការៈមិនប្រក្រតីរបស់ភ្នែកដែលមិនអាចញែកពណ៌បាន។

អ. achromatopsia

បារ. achromatopsie ( f. )

**អក្រូម៉ាស៊ី** អាការៈមិនប្រក្រតីរបស់ស្បែកដែលបាត់ជាតិពណ៌។

អ. achromasia

បារ. achromasie ( f. )

**អក្រូមី** ការថយចុះឬការបាត់ជាតិពណ៌របស់ស្បែក។

អ. achromia

បារ. achromie ( f. )

**អក្លរីឌ្រី** អាការៈមិនប្រក្រតីដោយគ្មានអាស៊ីដក្លរីឌ្រិកក្នុងរសក្រពះ។

អ. achlorhydria

បារ. achlorhydrie/ anachlorhydrie ( f. )

**អគីលី** អវត្តមានអាស៊ីដក្លរីឌ្រិកក្នុងរសក្រពះ។

អ. achylia

បារ. achylie( f. )

**អង់ដូមេទ្រីយ៉ូម** ដុំពកស្លូត( tumeur b́enigne )នៃភ្នាសក្នុងស្បូន (endomètre) ដែលមានរាងមូលៗ មានស្រោមដូចណ្ឌូឌូល (nodule)។

អ. endometrioma

បារ.endométriome ( m. )

**អង់ដូមេទ្រីយ៉ូស** វត្តមានជាលិកាភ្នាសក្នុងស្បូន (endomètre) នៅទីតាំងខុសប្រក្រតី ដូចជានៅក្នុងដៃស្បូន (trompe de fallope) សាច់ដុំស្បូន (myomètre) ឬ នៅក្រៅស្បូន ជាដើម។

អ. endometriosis

បារ. endométriose (f. )

**អង់ទីករ/អង្គបដិបក្ខ** សារធាតុប្រូតេអ៊ីនដែលផលិតដោយសរីរាង្គដើម្បីប្រឆាំងនឹងជំងឺទៅតាមប្រភេទពិសេសរបស់វា។ ឧ. ក្រោយពីចាក់វ៉ាក់សាំងបង្ការជំងឺកញ្ជ្រឹល កុមារនឹងមានអង់ទីករទប់ទល់នឹងជំងឺកញ្ជ្រឹលបាន។

អ. antibody

បារ. anticorps ( m. )

**អង់ទីតុកស៊ីន/ បដិវិសជាតុ**
អ. antitoxin
បារ. antitoxine (f.)

សារធាតុដែលអាចបន្សាបសកម្មភាពពុលរបស់តុកស៊ីន។

**អង់ទីប្យូទិក**
អ. antibiotic
បារ. antibiotique (m.)

សារធាតុឱសថមានប្រភពពីធម្មជាតិឬពីសារធាតុគីមី ឬ ការធ្វើសំយោគ ដែលមានសកម្មភាពអាចទប់ស្កាត់ការលូតលាស់ ឬ បំផ្លាញពពួកបាក់តេរីឬផ្សិត។ ឧ. គ្រូពេទ្យបានជ្រើសរើសឱសថអង់ទីប្យូទិកមួយប្រភេទមកព្យាបាលជំងឺរលាកបំពង់ក។

**អង់ហ្ស៊ីន**
អ. angina
បារ. angine (f.)

អាការៈឈឺចាប់ខ្លាំងក្លាបណ្ដាលមកពីការកន្ត្រាក់សាច់ដុំ (spasme) នៅត្រង់ចំណុចណាមួយនៃសរីរាង្គ។

**អង់ហ្ស៊ីយ៉ូម**
អ. angioma
បារ. angiome (m.)

ដុំពកបេនីញនៃសរសៃឈាម (vaisseau sanguin) និង សរសៃឡាំហ្វ៍ (vaisseau lymphatique) ពីកំណើតមានលក្ខណៈរីករវាមដួនកាលដុះលយចេញក្រៅសរីរាង្គ។

**អចលនា**
អ. akinesia
បារ. acinésie (f.)/ akinésie (f.)

អាការៈមិនប្រក្រតីដែលសាច់ដុំពុំអាចកន្ត្រាក់បាន។

**អដ្ឋិវិទ្យា**
អ. osteology
បារ. ostéologie (f.)

វិទ្យាសាស្ត្រសិក្សាជាមូលដ្ឋានអំពីឆ្អឹងរបស់មនុស្ស និង សត្វ។ ឧ. អដ្ឋិវិទ្យាជាផ្នែកមួយរបស់កាយវិភាគវិទ្យា/អាណាតូមី (anatomie)។

**ឥតអារ/ហ្វែទីល**
អ. fertile
បារ. fertile (adj.)

ដែលបង្កកំណើតបាន(មនុស្ស សត្វ និង រុក្ខជាតិ)។ ឧ. ស្ត្រីឥតអារអាចបង្កកំណើតបានចាប់ពីវ័យពេញក្រមុំរហូតដល់ពេលអស់រដូវ។

**អត្រាមរណៈ**
អ. mortality rate
បារ. taux de mortalité

ចំនួនមនុស្សស្លាប់ក្នុងចំណោមប្រជាពលរដ្ឋនៃប្រទេសឬតំបន់ណាមួយតាមឯកតាភាគរយ ភាគពាន់ឬភាគលានក្នុងរយៈពេលណាមួយ។ ឧ. អត្រាមរណៈជាស្តង់ដាសម្រាប់វាស់កម្រិតបច្ចេកទេសសុខាភិបាលនៃប្រទេស ឬ តំបន់ណាមួយ។

**អត្រាមរណៈទារកក្រោយកើត**
អ. postpartum mortality rate
បារ. taux de mortalité post partum/taux de mortalité postnatale

អត្រានៃទារកដែលស្លាប់នៅក្រោយពេលសម្រាល។ ឧ. ឆ្មបដែលមានវិជ្ជាជីវៈច្បាស់លាស់អាចកាត់បន្ថយអត្រាមរណៈទារកក្រោយកើត។

**អត្រាមរណៈទារកពេលកើត**
អ. perpartum mortality rate
បារ. taux de mortalité per partum

អត្រានៃទារកដែលស្លាប់នៅពេលកំពុងសម្រាល។ ឧ. បច្ចុប្បន្ននេះបច្ចេកទេសសង្គ្រោះទារកពេលសម្រាលមានការរីកចម្រើនខ្លាំងធ្វើឱ្យអត្រាមរណៈទារកពេលកើតថយចុះ។

**អត្រាមរណៈទារកមុនកើត**
អ. prenatal mortality rate
បារ. taux de mortalité prénatale

អត្រានៃទារកដែលស្លាប់ក្នុងផ្ទៃម្ដាយមុនពេលសម្រាល។ ឧ. ស្ត្រីមានគភ៌ត្រូវទៅពិនិត្យផ្ទៃពោះជាមួយគ្រូពេទ្យជំនាញដើម្បីកាត់បន្ថយអត្រាមរណៈទារកមុនកើត។

**អត្រាមរណៈមាតា**
អ. mother mortality rate
បារ. taux de mortalité maternelle

អត្រានៃស្ត្រីមានគភ៌ដែលស្លាប់ក្នុងអំឡុងពេលសម្រាល។ ឧ. ដើម្បីកាត់បន្ថយអត្រាមរណៈមាតា ស្ត្រីមានគភ៌ត្រូវពិគ្រោះជាមួយគ្រូពេទ្យតាមការកំណត់ ជាពិសេសស្ត្រីដែលមានជំងឺប្រចាំកាយធ្ងន់ធ្ងរ ដូចជាជំងឺទឹកនោមផ្អែម ជំងឺបេះដូង ជំងឺឡើងសម្ពាធឈាម ជំងឺសួតជាដើម។

**ឱនារូបត្ថម្ភ/កង្វះអាហារូបត្ថម្ភ** ភាពទទួលអាហារមិនគ្រប់គ្រាន់។

អ. starvation

បារ. sous alimentation/ sous nutrition

**អប្រាស៊ី** វិរូបភាពគ្មានដៃពីកំណើត។

អ. abrachia

បារ. abrachie (f.)

**អប្រាស្យ៉ូសេហ្វាលី** វិរូបភាពចម្លែកដោយគ្មានដៃនិងគ្មានក្បាលពីកំណើត។

អ. abrachiocephalia

បារ. abrachiocé-phalie (f.)

**អមូត្រ** អាការៈគ្មានទឹកនោមក្នុងប្លោកនោម។

អ. anuria

បារ. anurie (f.)

**អវត្តមាន/អាប់សង់** អាការៈបាត់ការចងចាំ និង អាចឈានដល់ការបាត់ស្មារតីមួយរយៈពេលខ្លីដោយសារកង្វះឈាមទៅចិញ្ចឹមខួរក្បាល។
(ពាក្យនេះ ប្រើក្នុងជំនាញជំងឺផ្លូវចិត្ត)។

អ. absence

បារ. absence (f.)

**ឱសថជំនួយកម្លាំង/អាណាឡិបទិក**
អ. analeptic
បារ. analeptique (m)

សារធាតុឱសថ ឬចំណីអាហារពិសេស ដែលធ្វើឱ្យមានកម្លាំងឡើងវិញ និងធ្វើឱ្យមានរំញោចប្រព័ន្ធប្រសាទកណ្ដាល ឬ សរីរាង្គដទៃទៀតរបស់សព៌ាង្គកាយ។

**ឱសថពន្យារកំណើត/កុងត្រាសិបទីហ្វ**
អ. contraceptive
បារ. contraceptif (m.)

ឱសថដែលមានប្រសិទ្ធភាពទប់ស្កាត់ការមានកំណាគភ៌នៅក្នុងផ្ទៃម្ដាយ។ ឧ. មុននឹងប្រើឱសថពន្យារកំណើត ស្ត្រីត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យឯកទេសដើម្បីបញ្ចៀសផលវិបាកទាំងឡាយពីការប្រើប្រាស់ឱសថនោះ។

**ឱសថលាងរបួស/អាប់ស្ទែហ្សង់**
អ. abstergent
បារ. abstergent (m.)

សារធាតុថ្នាំផ្សេងៗប្រើសម្រាប់លាងសម្អាតរបួស។

**អសេហ្វាលី**
អ. acephalia
បារ. acéphalie (f.)

វិរូបភាពគ្មានក្បាលមួយចំណែកឬទាំងមូលពីកំណើត។

**អ៊ីដ្រូណេហ្វ្រូស**
អ. hydronephrosis
បារ. hydronéphrose (f.)

អាការៈចាល់ទឹកនោមក្នុងវក្កំ(តម្រងនោម)ដែលគ្មានអាំងហ្វិចស្យុងដោយសារការស្ទះបំពង់ទឹកនោម (uretère)ដូចជាក្នុងករណីមានក្រួសឬទុយម័រ។

**អាកត្រូស**
អ. arthrosis
បារ. arthrose (f.)

អាការៈខូចសន្លាក់រ៉ាំរ៉ៃដោយគ្មានរោគសញ្ញារលាកដែលបង្កឱ្យសន្លាក់នោះចុះខ្សោយឬគាំង។ ជាទូទៅអាការៈនេះច្រើនកើតនៅសន្លាក់ជង្គង់ ឬ សន្លាក់ត្រគាកចំពោះមនុស្សមានវ័យលើសពី៥០ឆ្នាំឡើងទៅ។

**អាកទែ/រោហិណី**
អ. artery
បារ. artère (f.)

សរសៃឈាមដែលនាំឈាមចេញពីបេះដូងទៅសរីរាង្គកាយ។ ឧ. សព៌ាង្គកាយមនុស្សឬសត្វមានបណ្ដាញអាកទែឬរោហិណីជាច្រើនប្រភេទ។

**អាក្រូឌីនី**
អ. acrodynia
បារ. acrodynie (f.)

អាការៈឈឺចុកចាប់នៅប្រអប់ដៃនិងប្រអប់ជើងនៃកុមារដែលមានអាយុពី៦ទៅ៨ឆ្នាំ។

**អាក្រូប៉ាតូវិទ្យា**
អ. acropathology
បារ. acropathologie (f.)

វិទ្យាសាស្ត្រសិក្សាពីជំងឺនៅផ្នែកចុងនៃសព៌ាង្គកាយ (extrémité de l'organisme)។

**អាក្រូប៉ាទី** ជំងឺដែលកើតមាននៅតែខាងចុងដៃ ចុងជើង និង ក្បាល។

អ. acropathy

បារ. acropathie ( f. )

**អាក្រូប៉ូស្ទីត** អាការៈរលាកផ្នែកខាងចុងស្បែកគ្របក្បាលលិង្គ។

អ. acroposthitis

បារ. acroposthite ( f. )

**អាក្រូមីគ្រី** អាការៈរួមតូចខុសប្រក្រតីនៃក្បាល ចុងដៃ និង ចុងជើងពីកំណើត។

អ. acromicria

បារ. acromicrie ( f. )

**អាក្រូមេលី** ផ្នែកខាងចុងដៃនិងជើង។

អ. acromelia

បារ. acromélie ( f. )

**អាក្រូមេហ្កាលី** អាការៈរីកធំខុសធម្មតានៃក្បាល ច្រមុះ ត្រចៀក អណ្តាត ព្រមទាំងឆ្អឹងចុងដៃ ចុងជើង និង មានគមកញ្ចឹងកធ្វើឱ្យឆ្អឹងទ្រូងរុញមកមុខ (cyphose cervico-dorsale avec saillie du sternum)។

អ. acromegaly

បារ. acromégalie ( f. )

**អាក្រូសក្លេរ៉ូស** អាការៈក្រិនស្បែកផ្នែកខាងចុងដៃ ចុងជើង និង ក្បាល។

អ. acrosclerosis

បារ. acrosclérose ( f. )

**អាក្រូសាំងដាក់ទីលី** វិរូបភាពដែលចុងម្រាមដៃ ឬ ចុងម្រាមជើងស្អិតជាប់គ្នាពីកំណើត។

អ. acrosyndactyly

បារ. acrosyndactylie (f.)

**អាក្រូសេហ្វាលី** វិរូបភាពនៃឆ្អឹងលលាដ៍ក្បាលដោយផ្នែកខាងមុខ និង សងខាងមិនលូតលាស់ធ្វើឱ្យទ្រង់ទ្រាយក្បាលមានរាងសំប៉ែត ហើយឆ្អឹងលលាដ៍ខាងក្រោយវិវត្តពយទៅក្រោយនិងទៅលើ។

អ. acrocephalia

បារ. acrocéphalie/ hypsocéphalie (f.)

**អាក្រូស្យាណូស** អាការៈមិនប្រក្រតីរបស់ស្បែកដោយចុងដៃចុងជើងឡើងពណ៌ខៀវស្លេកជាប្រចាំ។ អាការៈនេះកម្រកើតមាននៅច្រមុះ ត្រចៀក ថ្ពាល់ និង ផ្នែកខាងក្រោយនៃដើមដៃ។

អ. acrocyanosis

បារ. acrocyanose (f.)

**អាក់ទីណូព្យាបាល** វិធីព្យាបាលជំងឺដោយប្រើកាំរស្មីស្វាយអ៊ុលត្រា (ultraviolet) កាំរស្មីក្រហមអាំងហ្វ្រា (infrarouge)...។

អ. actinotherapy

បារ. actinothérapie (f.)

**អាក់ទីណូមហារីក** ជំងឺមហារីកស្បែកដែលបង្កឡើងដោយរំភាយរស្មីព្រះអាទិត្យ។

អ. actinocancer

បារ. actinocancer (m.)

**អាក់ទីណូវិទ្យា**
អ. actinology
បារ. actinologie (f.)

វិទ្យាសាស្ត្រសិក្សាអំពីផលប៉ះពាល់នៃរំភាយរស្មី ជាពិសេសកាំរស្មីស្វាយអ៊ុលត្រា (ultraviolet) ក្រហមអាំងហ្វ្រា (infrarouge)...នៃព្រះអាទិត្យ ក្នុងផ្នែកជីវវេជ្ជសាស្ត្រ។

**អាក់ទីនីត**
អ. actinitis
បារ. actinite (f.)

អាការៈរលាកស្បែកដែលបង្កឡើងដោយរំភាយរស្មីព្រះអាទិត្យ។

**អាក់ទីវ៉ាទ័រ**
អ. activator
បារ. activateur (m.)

វត្ថុធាតុរូបឬគីមី (élément pysique ou chimique) ដែលជួយពន្លឿនជីវប្រតិកម្ម (reaction biologique)។

**អាក់ទីវ៉ាស្យុង**
អ. activation
បារ. activation (f.)

ការពន្លឿនជីវប្រតិកម្មដោយប្រើអាក់ទីវ៉ាទ័រ។

**អាក់សែ**
អ. access
បារ. accès (m.)

អាការៈជំងឺកើតឡើងយ៉ាងទាន់ហន់ខ្លាំងក្លាដែលមានរយៈពេលខ្លីជាបន្តបន្ទាប់ និង ទៀងទាត់។

**អាគូទុយម៉ង់**
អ. acquired tolerance

បាតុភូតនៃសរីរាង្គមិនឆ្លើយតបនឹងការប្រើឱសថគ្រឿងពុល ឬ គ្រឿងញៀន ដែលតម្រូវឱ្យប្រើពីកម្រិតទាបទៅខ្ពស់ដើម្បីទទួលបាននូវប្រសិទ្ធភាព។

បារ. accoutumance (f.) ៤. អាគូទុយម៉ង់ថ្នាំងុយដេកតម្រូវឱ្យដំឡើងបរិមាណឱសថទើបទទួលបានប្រសិទ្ធភាព។

**អាគូម៉ែត្រ**
អ. acoumeter
បារ. acoumètre (m.)
ឧបករណ៍វេជ្ជសាស្ត្រសម្រាប់វាស់សំឡេងដែលត្រចៀកអាចស្ដាប់ឮ។

**អាគូមេទ្រី**
អ. acoumetry
បារ. acoumétrie (f.)
ការវាស់សំឡេងដែលត្រចៀកអាចស្ដាប់ឮដោយប្រើអាគូម៉ែត្រ។

**អាគូស្ទិក**
អ. acoustic
បារ. acoustique (adj.)
ដែលជាប្រព័ន្ធសរសៃប្រសាទដែលទាក់ទងគ្នារវាងត្រចៀក និង ខួរក្បាល។

**អាគូស្មាតាញ៉ូស៊ី**
អ. acousmatagnosis
បារ. acousmatagnosie (f.)
ជំងឺថ្លង់ម្យ៉ាងដែលបណ្ដាលមកពីប្រព័ន្ធសរសៃប្រសាទកណ្ដាលមិនអាចចាប់ ឬ ដឹងសំឡេងអ្វីមួយបានច្បាស់។

**អាគូហ្វែន**
អ. tinnitus
បារ. acouphène (m.)
អាការៈមិនប្រក្រតីរបស់ត្រចៀក ដែលហ៊ឹងហើយឮសំឡេងប្លែកៗខុសពីសំឡេងរំញោចពីខាងក្រៅ។

**អាគ្វីតេ** សមត្ថភាពនៃវិញ្ញាណដែលអាចវិនិច្ឆ័យអ្វីៗដែលតូចឬតិចបំផុត។
អ. acuteness /acuity
បារ. acuité (f.)

**អាគ្វីតេគំហើញ** សមត្ថភាពនៃចក្ខុវិញ្ញាណដែលអាចមើលឃើញរូបភាពតូចបំផុតបាន។
អ. visual acuity
បារ. acuité visuelle

**អាគ្វីតេល្បឺ** សមត្ថភាពនៃសោតវិញ្ញាណដែលអាចទទួលសំឡេងតិចបំផុតបាន។
អ. auditory acuity
បារ. acuité auditive (f.)

**អាដ្រេណាលីន** អ័រម៉ូនម្យ៉ាងដែលបញ្ចេញដោយក្រពេញស្មួរ៉េណាល់ (glande surrénale)។ គេអាចផលិតអាដ្រេណាលីនសិប្បនិម្មិតបានដើម្បីប្រើក្នុងផ្នែកវេជ្ជសាស្ត្រ។
អ. adrenaline
បារ. adrénaline (f.)

**អាណាហ្វីឡាស៊ី** ប្រតិកម្មនៃសរីរាង្គទៅនឹងសារធាតុពីក្រៅតាមការលេប ការចាក់ ការហិត ឬ ការប៉ះពាល់ ដែលបង្កជារោគសញ្ញាផ្សេងៗដូចជា ឡើងកន្ទួលរមាស់លើស្បែក កណ្តាស់ឬអាចបណ្តាលឱ្យស្តុក (choc) និង/ឬ រហូតដល់ស្លាប់ក៏មាន។
អ. anaphylaxis
បារ. anaphylaxie (f.)

**អាណេវ្រីស**
អ. aneurysm
បារ. anévrisme/ anévrysme (m)

អាការៈរីកប៉ោងភ្នាសសរសៃឈាមដែលបង្កឱ្យកើតមានជាអាតេរ៉ូម។

**អាតេរ៉ូម**
អ. atheroma
បារ. athérome (m.)

១-គីស្ត(kyste)កើតឡើងដោយសារកំណាកខ្ទុះនៃមុន(acné)។
២-កំណាកសារជាតុខ្លាញ់នៅភ្នាសក្នុងនៃអាកទែដែលបង្កឱ្យឡើងសម្ពាធឈាម។

**អាប់រេអាក់ស្យុង**
អ. abreaction
បារ. abréaction (f.)

សភាពចិត្តរបស់អ្នកមានវិបត្តិផ្លូវចិត្តដែលកើតឡើងវិញនូវស្មារតីចងចាំចំពោះហេតុការណ៍ដែលបានភ្លេចបាត់ពីពេលកន្លងមក។

**អាប់សែ**
អ. abscess
បារ. abcès (m.)

ការបង្កខ្ទុះនៅក្នុងជាលិកាដែលរលួយខូចដោយ-សារមេរោគ។ ឧ. អាប់សែថ្លើមបណ្ដាលមកពីបរាសិត ដែលជាអាមីប ឈ្មោះ អង់តាមីបាអ៊ីស្តូលីទីកា (entamœba histolytica)។

**អាម៉្ញូស**
អ. amnion/amnios
បារ. amnios (m.)

ស្រទាប់ក្នុងនៃភ្នាសរុំព័ទ្ធទារកដែលអភិវឌ្ឍទៅតាមការរីកធំធាត់របស់ទារកនៅក្នុងផ្ទៃម្ដាយ។
ឧ. នៅពេលប្រសូត អាម៉្ញូសកើតចេញមកជាមួយនឹងទារក។

**អាមីប**
អ. amoeba
បារ. amibe (f.)

បរាសិតឯកកោសិកាមានក្បាល ដងខ្លួន និង កន្ទុយ អាចធ្វើចលនាបានយ៉ាងរហ័ស ដែលជាភ្នាក់ងារបង្កជំងឺមួលឈាម (dysentérie amibienne)។

**អាយុ**
អ. age
បារ. âge (m.)

រយៈពេលនៃជីវិតរស់នៅរបស់បុគ្គលណាមួយ ចាប់ពីថ្ងៃកើតដល់ពេលណាមួយ ឬ ដល់ថ្ងៃស្លាប់។

**អារ**
អ. sterile
បារ. stérile (adj.)

ដែលមិនអាចបង្កកំណើតបាន (មនុស្ស សត្វ និង រុក្ខជាតិ)។ ឧ. គូស្វាមីភរិយាដែលរៀបការយូរពេល ហើយមិនមានកូនអាចបណ្តាលមកពីប្តីនិង/ឬ ប្រពន្ធអារ។

**អារនីយកម្ម**
អ. sterilization
បារ. stérilisation (f.)

វិធីសាស្ត្រធ្វើឱ្យមានភាពអារដល់បុរសឬស្ត្រី។ ឧ. វិធីវះកាត់ចងដៃស្បូនជាអារនីយកម្មមួយបែបដល់ស្ត្រី។

**អាសន្នរោគ**
អ. cholera
បារ. choléra (m.)

រោគបង្កឡើងដោយមេរោគឈ្មោះ Vibrio cholerae ដែលរកឃើញដោយ លោក Robert Koch នៅ គ.ស.១៨៨៣។ ជំងឺនេះឆ្លងតាមផ្លូវអាហារ ជាពិសេសទឹកមិនស្អាត និង ឆ្លងតាមដៃ បណ្តាលឱ្យមានការចុះរាកយ៉ាងខ្លាំងជាច្រើនដងមិនឈប់ និង មានការក្អួតយ៉ាងខ្លាំងផងដែរ ជាហេតុបណ្តាល

ឱ្យខ្វះជាតិទឹក ឬ ខ្សោះជាតិទឹកពីក្នុងខ្លួនអ្នកជំងឺ អាចបណ្ដាលឱ្យស្លាប់ ប្រសិនបើមិនបានព្យាបាល ទាន់ពេលវេលា តាមក្បួន តាមជំនាញនោះទេ។

២. មណ្ឌលសុខភាពបានអប់រំប្រជាពលរដ្ឋឱ្យរស់នៅស្អាត ហូបស្អាត ផឹកស្អាត មានអនាម័យ ដើម្បីជៀសវាងការកើតជំងឺអាសន្នរោគ។

**អាស៊ីដូស**
អ. acidosis
បារ. acidose ( f. )

អាការៈមិនប្រក្រតីដោយមានអតុល្យភាពអាស៊ីដបាសនៃប្លាស្មាក្នុងឈាមដែលកម្រិតpHតូចជាង ៧,៤០។

**អាស៊ីដូរី**
អ. aciduria
បារ. acidurie ( f. )

វត្តមានអាស៊ីដច្រើនលើសលប់ក្នុងទឹកមូត្រ។

**អាស៊ីដេមី**
អ. acidaemia
បារ. acidémie( f. )

ភាពចុះទាបជាងធម្មតានៃកម្រិតpH( ៧,៤០ ) របស់ឈាម។

**ទាចទឹក/អាស៊ីត**
អ. ascites
បារ. ascite ( f. )

វត្តមានទឹកនិងអេឡិចត្រូលីត នៅក្នុងភ្នាសពោះ បណ្ដាលមកពីមូលហេតុច្រើនយ៉ាង ដូចជាក្រិនថ្លើម របេងភ្នាសពោះ ជំងឺបេះដូង...។

**អាសេតូន** សារធាតុអាស៊ីដសរីរាង្គកើតឡើងដោយសារ-
អ. acetone( ketone) អុកស៊ីដកម្ម អាស៊ីដខ្លាញ់ក្នុងសរីរាង្គកាយ ដែល
បារ. acétone ( f. ) ជាធម្មតា មានបរិមាណតិចតួចនៅក្នុងឈាម និង ទឹកមូត្រ។

**អាសេតូនូរី** វត្តមានអាសេតូននៅក្នុងទឹកមូត្រ។
អ. acetonuria
បារ. acétonurie ( f. )

**អាសេតូនេមី** វត្តមានអាសេតូននៅក្នុងឈាម។
អ. acetonaemia
បារ. acétonémie ( f. )

**អាស្បេស្តូស** ជំងឺធូលីសួតម៉្យាង បង្កឡើងដោយការដកដង្ហើម
អ. asbestosis ស្រូបចូលផង់អាម៉្យង់ (amiante) ផង់ម៉ាញេ-
បារ. asbestose ( f. ) ស្យូមស៊ីលីកាត (silicate de magnésium) ផង់ ដែកអុកស៊ីដ (oxidede fer)...ដែលប្រើក្នុង ឧស្សាហកម្ម។

**អូតូក្លាវ** ទូឬធុងផ្ចាំងពិសេសសម្រាប់ធ្វើស្តេរីលកម្មសម្ភារៈ
អ. autoclave វេជ្ជសាស្ត្រឬសម្ភារៈផ្សេងៗ ដោយប្រើចំហាយទឹក
បារ. autoclave ( m. ) ដែលមានកម្តៅនិងសម្ពាធខ្ពស់។

**អូវុល**
អ. ovule
បារ. ovule (m.)

កោសិកាបន្តពូជញីដែលផលិតចេញពីសរីរាង្គបន្តពូជ (អូវែ : ovaire) របស់មនុស្សស្រី សត្វញី ឬរុក្ខជាតិញី។ ឧ. ការបង្កកំណើតរបស់មនុស្ស សត្វ ឬរុក្ខជាតិកើតឡើងដោយការរួមផ្សំគ្នារវាងស្ពែម៉ាតូ-សូអ៊ីត (spermatozoïde) ឬ អង់តេរ៉ូសូអ៊ីត (anthérozoïde) និង អូវុល។

**អូវែ**
អ. ovary
បារ. ovaire (m.)

ក្រពេញភេទរបស់មនុស្សស្រី សត្វញី ឬ រុក្ខជាតិញី។ នៅពេលពេញវ័យ ក្រពេញភេទនេះ អាចផលិតអូវុល និង អ័រម៉ូនអឺស្ត្រូហ្សែន និងប្រូហ្សេសស្តេរ៉ូន។ ឧ. អូវែរបស់មនុស្សស្រីចាប់ផ្តើមបញ្ចេញអូវុលនៅពេលស្ត្រីពេញវ័យ។

**អៀន**
អ. pinworm
បារ. oxyure (m.)

បរាសិតណេម៉ាតូដ(nématodes)មានប្រវែងពី៤ទៅ៩មីល្លីម៉ែត្ររស់នៅក្នុងបំពង់អាហារជាពិសេសនៅចុងពោះវៀនធំ និងទ្វារលាមក ដែលបង្កឱ្យរមាស់។ ឧ. ក្មេងកើតអៀនច្រើនរមាស់ទ្វារធំនៅពេលយប់។

**អេម៉ង់ហ្សីយ៉ូម**
អ. hemangioma
បារ. hémangiome (m.)

អង់ហ្សីយ៉ូមនៃសរសៃឈាម(vaisseau sanguin)។ ប្រជាជនខ្មែរនិយមហៅអេម៉ង់ហ្សីយ៉ូមនៅលើស្បែកដែលមានលក្ខណៈពកតូចៗថាជាខ្នៅដុះពណ៌ក្រហម។

**អេម៉ាតូម**
អ. hematoma
បារ. hématome (m.)

កំណកឈាមជាដុំៗនៅក្នុងជាលិកា ឬ ក្នុងសរីរាង្គ ដោយមិនមានរហែកស្បែកបណ្តាលមកពីរបួសសរសៃឈាម ឬ ការប៉ះទង្គិចធ្ងន់ធ្ងរ។

**អេរីតែម/ស្បែកឡើងក្រហម**
អ. erythema/ erythro derma
បារ. érythème (m.)

អាការៈស្បែកប្រែជាក្រហមតិចឬច្រើនដោយសារកម្តៅថ្ងៃឬប្រតិកម្មអាឡែហ្ស៊ី (réaction allergique)។ ឱ. ដើម្បីបញ្ជាក់ថាជាអេរីតែម គេអាចធ្វើតេស្ត ដោយសង្កត់ចំកន្លែងស្បែកពណ៌ក្រហមនោះ វាឡើងសស្លេក ប៉ុន្តែវាត្រឡប់មកសភាពដើមវិញ នៅពេលគេដកដៃចេញ។

**អំប្រ៊ីយ៉ុង/ក្រូណា**
អ. embryo
បារ. embryon (m.)

គភ៌ដែលមានអាយុក្នុងរយៈពេលបីខែដំបូង។ ឱ. ដើម្បីបញ្ចៀសការរលូត ស្ត្រីដែលមានគភ៌ជាអំប្រ៊ីយ៉ុងត្រូវប្រុងប្រយ័ត្នចំពោះការប្រើឱសថមិនបានត្រឹមត្រូវ ឬ ជៀសវាងគ្រោះថ្នាក់ចៃដន្យផ្សេងៗ។

**អំបៅអំបែក**
អ. otitis media
បារ. otite moyenne

ជំងឺម៉្យាងដែលកើតក្នុងរន្ធត្រចៀកបង្កឡើងដោយមីក្រូសព៌ាង្គកាយ។ រោគសញ្ញាមានដូចជាក្តៅខ្លួន ឈឺក្នុងរន្ធត្រចៀក ហៀរទឹករងៃ ឬ ខ្ទុះ ដែលមានក្លិនស្អុយ។

**អំពូតាស្យុង** ការកាត់ចោលតាមវិធីវេជ្ជសាស្ត្រនូវផ្នែកណាមួយ
អ. amputation នៃអវយវៈឬសរីរាង្គខាងក្រៅ។
បារ. amputation ( f. )